នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក-អជសស/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
04 / 05 / 2020
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé
SANN RADA

---

# បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ
# ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ:**
លោកស្រី Brenda J. HOLLIS

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C.N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហមេធាវីការពារក្តី អោ អាន:**
មុំ លុជ
Richard ROGERS
Göran SLUITER

**អ្នកទទួលឯកសារ:**
**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ហុង គឹមសួន
ឡោ ជុនធី
សំ សុគង់
ស៊ិន សោវ៉ន
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI
ជេត វណ្ណលី
គីម ម៉េងឃី
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGE
Isabelle DURAND
Lyma NGUYEN

## I. សេចក្តីផ្តើម និង ប្រវត្តិ

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ប្តឹងសាទុក្ខចំពោះការរំលត់ជាធរមាននៃ សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ប្រឆាំងនឹង អោ អាន ។ ដូចបានរៀបរាប់យ៉ាងលម្អិតខាងក្រោម អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") បានបដិសេធម្តងហើយម្តងទៀតក្នុងការចាប់ផ្តើមសវនាការជំនុំជម្រះលើសំណុំរឿង ០០៤/២ តាំងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ មក នៅពេលដែលអង្គបុរេជំនុំជម្រះ ("អ.ប.ជ") មិនអាចរកបានសំឡេងភាគច្រើនលើសលុបបាន ដើម្បីទាត់ចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ពេលនោះ សេចក្តីសម្រេចជាស្វ័យប្រវត្តិដែលបានផ្តល់អាណត្តិដោយកិច្ចព្រម ព្រៀង អ.វ.ត.ក[1] ច្បាប់ អ.វ.ត.ក[2] និងវិធានផ្ទៃក្នុង[3] ត្រូវបានបញ្ចេះឡើង ដោយបានប្តឹងយ៉ាងស្របច្បាប់ឲ្យ អ.ជ.ស.ដ ទទួលយកសំណុំរឿងនេះទៅចាត់ការបន្ត។

2. យ៉ាងណាមិញ អ.ប.ជ បានបដិសេធមិនជូនដំណឹងជាផ្លូវការ ឬសម្រេចលើសេចក្តីថ្លែងសំអាងរបស់គូភាគីដែលមានជាបន្តបន្ទាប់ ដែលសុទ្ធតែពាក់ព័ន្ធនឹងដំណើរការសវនាការ ព្រមទាំងសំណើជាច្រើនរបស់ ស.ព.អ ដែលស្នើឲ្យចាត់វិធានការចាំបាច់នានាទាំងអស់ ដើម្បីធ្វើយ៉ាងណាឲ្យសំណុំរឿងនេះបានទៅដល់ការជំនុំជម្រះ។ ពីដំបូង អ.ជ.ស.ដ បានផ្តល់យុត្តិកម្មចំពោះការខកខានរបស់ខ្លួនថា ដោយសារតែខ្លួនមិនត្រូវបានជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណារបស់ អ.ប.ជ ហើយខ្លួនក៏មិនបានទទួលសំណុំរឿងនេះ។ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធាន អ.ប.ជ បានបញ្ជាក់យ៉ាងច្បាស់ថា អ.ប.ជ គ្មាននៅសល់កិច្ចអ្វីដែលត្រូវបំពេញជាបន្តទៀតនោះទេទាក់ទងនឹងសំណុំរឿង ០០៤/២។ ដូច្នេះ ស.ព.អ សូមស្នើឲ្យ អ.ជ.ស.ដ ធ្វើយ៉ាងណាឲ្យសំណុំរឿងនេះបានទៅដល់ការជំនុំជម្រះដោយរួមទាំងការប្រកាសតាមផ្លូវតុលាការ ចំពោះបញ្ហាដែលស្ថិតនៅចំពោះមុខខ្លួនផង។ អ.ជ.ស.ដ បានឆ្លើយតបយ៉ាងឆាប់រហ័ស តាមរយៈការចេញសេចក្តីថ្លែងការណ៍រួមមួយ ("សេចក្តីថ្លែងការ ចុះថ្ងៃទី ៣ ខែមេសា") ដោយខ្លួនបានប្រកាសថា "គ្មានកម្លាំងផ្លូវច្បាប់" ប៉ុន្តែបានយោងនូវយុត្តិកម្មដូចគ្នា

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក"), មាត្រា ៥(៤), ៦(៤), ៧(៤)។

[2] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តី ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ដែលបានកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក"), មាត្រា ២០ថ្មី, ២៣ថ្មី។

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") ឬ ("វិធាន"), វិធាន ៧៧(១៣)(ខ), ៧៩(១)។

សម្រាប់ភាពនៅស្ងៀមជាបន្តរបស់ខ្លួន។ ការខកខានរបស់ អ.ជ.ស.ដ ក្នុងការបំពេញកិច្ចតាំងពីថ្ងៃទី ១៩ ខែធ្នូ និងចេតនាយ៉ាងច្បាស់ក្រឡែតរបស់ខ្លួនដូចបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការ ចុះថ្ងៃទី៣ ខែមេសា ដើម្បីបន្តភាពនៅស្ងៀមនោះ បានរំលត់យ៉ាងមានប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី។

3. ស.ព.អ សន្និដ្ឋានថា អ.ជ.ស.ដ មានការភាន់ច្រឡំផ្នែកច្បាប់ និងបានបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការរំលត់យ៉ាងមានប្រសិទ្ធិភាពលើសំណុំរឿង ០០៤/២ ដែលតម្រូវឲ្យមានអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”)។ ដូចបានរៀបរាប់យ៉ាងលម្អិតខាងក្រោម អ.ជ.ស.ដ i) ខកខានក្នុងការផ្តល់អនុភាពទៅលើគោលជំហរស្វ័យប្រវត្តិចំពោះសំណុំរឿងនេះដែលបានប្តឹងមកខ្លួន គិតត្រឹមថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩; ii) ខកខានមិនបានសំអាងលើយុត្តាធិការច្បាប់ និងយុត្តាធិការដែលមានជាប់មកជាមួយក្នុងការអនុវត្តកាតព្វកិច្ចតុលាការជាបឋមរបស់ខ្លួន ដើម្បីប្រកាសលើបញ្ហាត្រឹមត្រូវតាមច្បាប់; iii) ដាក់លក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលបន្ថែមដោយចិត្តឯង ធ្វើឲ្យមានឥទ្ធិពល អនុភាពទៅលើការជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណារបស់ អ.ប.ជ និង iv) បានរំលត់សំណុំរឿងនេះយ៉ាងមានប្រសិទ្ធិភាព ដោយឈរលើទឡ្ហីករណ៍ដែលមិនត្រូវបានអនុញ្ញាត។ កំហុសទាំងនេះបានធ្វើឲ្យមោឃៈដល់ការរំលត់សំណុំរឿងជាធរមាន និងជាបុរេនិច្ឆ័យចំពោះ ស.ព.អ និងគូភាគីផ្សេងទៀតនៃសំណុំរឿង ០០៤/២ ដោយសារវាបានរំលោភសិទ្ធិជាមូលដ្ឋានរបស់ភាគីក្នុងការទទួលបាននូវភាពត្រឹមត្រូវយុត្តិធម៌ខាងផ្នែកនីតិវិធី សច្ចភាពផ្លូវច្បាប់ តម្លាភាព សិទ្ធិប្តឹងសាទុក្ខ និងសិទ្ធិធ្វើសវនាការចំពោះមុខចៅក្រមមិនលំអៀង និងឯករាជ្យ។ ប្រសិនបើ អ.ប.ជ បានអនុវត្តច្បាប់ត្រឹមត្រូវ និង/ឬប្រើឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ ម្ល៉េះសំណុំរឿង ០០៤/២ បានទៅដល់ការជំនុំជម្រះហើយ។

4. អាស្រ័យហេតុនេះ ស.ព.អ សូមដាក់បណ្តឹងសាទុក្ខបន្ទាន់នេះ អនុលោមតាមវិធាន ១០៤(៤)(ក) និងក្នុងប្រយោជន៍នៃយុត្តិធម៌។ ភាពនៅស្ងៀមដែលចេះតែមានជាបន្តរបស់ អ.ជ.ស.ដ ដែលធ្វើឲ្យរលត់សំណុំរឿងយ៉ាងមានប្រសិទ្ធិភាព តម្រូវឲ្យមានអន្តរាគមន៍ពី អ.ជ.ត.ក ដើម្បីធានាបាននូវសុចរិតភាពរបស់ អ.វ.ត.ក ក្នុងនាមជាស្ថាប័នតុលាការឯករាជ្យដែលសម្រេចសេចក្តីដោយផ្អែកលើអង្គច្បាប់ និងអង្គហេតុ ព្រមទាំងដើម្បីធានាចំពោះសិទ្ធិរបស់គូភាគីទាំងអស់ ដើម្បីផ្តល់នូវយុត្តិធម៌តាមកិច្ចដំណើរការនីតិវិធីរបស់តុលាការដែលមានតម្លាភាព។

## II. ប្រវត្តិនីតិវិធី

5. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) បានចេញដីកាដំណោះស្រាយរបស់ខ្លួន ទាក់ទងនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤/២៖ សហចៅក្រមស៊ើបអង្កេតអន្តរ

ជាតិ ("ស.ច.ស.អ") បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[4] ខណៈដែលសហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាសម្រេចលើកលែងចោទប្រកាន់[5]។ បន្ទាប់មក ភាគីបានដាក់សារណាបណ្ដឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរ និងបានធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ជូន អ.ជ.ប ដោយបានជំទាស់លើកំហុសនានា និងអង្គសេចក្ដីនៃដីកាដំណោះស្រាយ ព្រមទាំងវិបាកផ្នែកនីតិវិធីដែលធ្វើឲ្យ អ.ប.ជ មិនអាចរកបានសំឡេងភាគច្រើនលើសលុបចំពោះបណ្ដឹងឧទ្ធរណ៍ទាំងនោះ[6]។

---

[4] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ), ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[5] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន, ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់")។

[6] ឯកសារ **D359/3** សៀវភៅចុះបណ្ដឹងឧទ្ធរណ៍នៃបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.ជ លើកលែងការចោទប្រកាន់ប្រឆាំងនឹង អោ អាន (D359), ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨។ ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359), ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359), ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។ ឯកសារ **D359/3/5** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359), ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។ ឯកសារ **D360/5** សៀវភៅចុះបណ្ដឹងឧទ្ធរណ៍នៃបណ្ដឹងឧទ្ធរណ៍លើ សេចក្ដីសម្រេចលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ), ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨។ ឯកសារ **D360/5/1** បណ្ដឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងសេចក្ដីសម្រេចលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ), ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨។ ឯកសារ **D360/9** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២, ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩។ ឯកសារ **D360/11** ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២, ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩។ ឯកសារ **D360/8** សៀវភៅចុះបណ្ដឹងឧទ្ធរណ៍នៃការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់ស.ច.ស.អ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ), ចុះថ្ងៃទី១២ ខែវិច្ឆកា ឆ្នាំ២០១៨។ ឯកសារ **D360/8/1** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង០០៤/២, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨។ ឯកសារ **D360/10** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៤/២, ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។ ឯកសារ **D359/8.1 & D360/17.1** ប្រតិចារឹកសវនាការនៃបណ្ដឹងឧទ្ធរណ៍, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩។ ឯកសារ **D359/9.1 & D360/18.1** ប្រតិចារឹកសវនាការនៃបណ្ដឹងឧទ្ធរណ៍, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩។ ឯកសារ **D359/10.1 & D360/19.1** ប្រតិចារឹកសវនាការនៃបណ្ដឹងឧទ្ធរណ៍, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។

6. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយបរាជ័យមិនអាចរកបានសំឡេងភាគច្រើនលើសលុបដែលតម្រូវ ដើម្បីកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់[7]។ សេចក្តីពិចារណារបស់ អ.ប.ជ បានដាក់ជាសាធារណៈ ហើយចៅក្រម Claudia Fenz និង Martin Karopkin ព្រមទាំងក្រឡាបញ្ជី អ.ជ.ស.ដ លោក លឹម ស៊ុយហុង ត្រូវបានចម្លងជូនក្នុងសារអេឡិចត្រូនិកនៃសេចក្តីជូនដំណឹងផ្លូវការនោះ[8]។ សារអេឡិចត្រូនិកដូចគ្នានេះក៏បានបញ្ជូនទៅ ស.ច.ស.ជ យូ ប៊ុនឡេង[9] ផងដែរ ដែលនៅពេលនោះគាត់គឺជាមន្ត្រី ឬបុគ្គលិកតែម្នាក់គត់ដែលនៅសល់ក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត[10]។

7. នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ យោងតាមវិធាន ៣៩(៤), ៧៧(១៣)(ខ), ៧៩(១) និង ៨០(១) ស.ព.អ បានដាក់សំណើមួយជាសំណៅរឹងជូន អ.ជ.ស.ដ ដោយសុំបន្ថែមពេលវេលាដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន និងសម្រាប់កិច្ចប្រជុំរៀបចំសវនាការ[11]។ ស.ព.អ ក៏បាន

---

[7] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ (“សេចក្តីពិចារណារបស់ អ.ប.ជ”)។

[8] *សូមមើល* សារអេឡិចត្រូនិកជូនដំណឹង ពីមន្ត្រីទទួលបន្ទុកសំណុំរឿង, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩, វេលាម៉ោង ៤:៥៣ រសៀល។ *(ភ្ជាប់ជាឧបសម្ព័ន្ធ ខ)*។

[9] *សូមមើល* សារអេឡិចត្រូនិកជូនដំណឹង ពីមន្ត្រីទទួលបន្ទុកសំណុំរឿង, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩, វេលាម៉ោង ៤:៥៣ រសៀល។ *(ភ្ជាប់ជាឧបសម្ព័ន្ធ ខ)*។

[10] *សូមមើល* របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, ចុះថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១៩, UN Doc. A/74/359, ទំព័រ ១៧, ឧបសម្ព័ន្ធ ១: សេចក្តីសង្ខេបនៃសកម្មភាពតាមដានដែលបានធ្វើឡើងដើម្បីអនុវត្តអនុសាសន៍ដែលពាក់ព័ន្ធ (“បន្ទាប់ពីការចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣, ០០៤ និង ០០៤/២ មុខតំណែងបុគ្គលិកទាំងអស់នៅការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ជូនសំណើលាលែងពីមុខតំណែងរបស់គាត់”)។ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ អគ្គលេខាធិការបានបន្តតំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើងវិញ។ *សូមមើល* សារអេឡិចត្រូនិកប្រកាសរបស់ UNAKRT, ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០, វេលាម៉ោង ១២:៥២ រសៀល *(ភ្ជាប់ជាឧបសម្ព័ន្ធ ញ)*។ https://eccc.gov.kh/en/articles/statement-international-co-investigating-judge-reinstated សម្រាប់សេចក្តីប្រកាសជាភាសាអង់គ្លេស។

[11] *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបន្ថែមពេលវេលាកំណត់ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង និងកិច្ចប្រជុំរៀបចំសវនាការ, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ដែលបានប្រគល់ជាសំណៅរឹងជូនក្រឡាបញ្ជី អ.ជ.ស.ដ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ *(ភ្ជាប់ជាឧបសម្ព័ន្ធ O1 (អង់គ្លេស) និង O2 (ខ្មែរ))*។ *សូមមើលផងដែរ* ឯកសារ **D359/36.2 & D360/45.2** ឯកសារភ្ជាប់ទី២ (សារអេឡិចត្រូនិក មានចំណងជើងថា “ព័ត៌មាន” បញ្ជូនដោយ ស៊ុយ ហុងលឹម ក្នុងនាម អ.ជ.ស.ដ), ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ (“សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា”) បានភ្ជាប់ទៅនឹង ឯកសារ **D359/36 & D360/45** អនុស្សរណៈរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងការបញ្ជូនសំណុំរឿង ០០៤/២, ចុះថ្ងៃទី១២

បញ្ជូនសំណៅចម្លងតាមរយៈសារអេឡិចត្រូនិកជូនចៅក្រម អ.ជ.ស.ដ ក្រឡាបញ្ជី និងគូភាគីនានាផង ដែរ។ ស.ព.អ បានអនុម័តិយកការអនុវត្តដូច្នេះសម្រាប់ដាក់ឯកសារផ្សេងៗទៀតជូន អ.ជ.ស.ដ នៅពេលក្រោយមក ដោយសារអង្គនុំជម្រះមិនដែលអនុញ្ញាតឲ្យមានមធ្យោបាយណាមួយដើម្បីដាក់ ឬ ជូនដំណឹងសារណាតាមអេឡិចត្រូនិក។

8. នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ អោ អាន បានស្នើឲ្យ អ.ជ.ស.ដ បញ្ជាក់ថា អ.ជ.ស.ដ មិនត្រូវបាន ប្ដឹងដោយស្របច្បាប់នៃសំណុំរឿង ០០៤/២ នេះទេ ឬតាមជម្រើសផ្សេង ឲ្យ អ.ជ.ស.ដ ផ្ដល់ការ ណែនាំឲ្យដាក់អញ្ញត្រកម្ម និងអនុញ្ញាតឲ្យ អោ អាន នូវពេលវេលាគ្រប់គ្រាន់ (យ៉ាងហោចណាស់ ៦០ ថ្ងៃ) ដើម្បីដាក់អញ្ញត្រកម្មរបស់គាត់[12]។ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំ នេះនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២០[13]។

9. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ដោយមិនទទួលបានការសម្រេចណាមួយពី អ.ជ.ស.ដ លើសំណើ សុំបន្ថែមពេលវេលាសម្រាប់ដាក់បញ្ជីឈ្មោះ (សាក្សី និងអ្នកជំនាញ) របស់ខ្លួន ស.ព.អ ក៏បានដាក់ បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន អនុលោមតាមវិធាន៨០(១) នៃវិធានផ្ទៃក្នុង ស្របតាម កាលបរិច្ឆេទដែលបានស្នើសុំពន្យារ[14]។

10. ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ស.ព.អ បានប្រគល់ដោយផ្ទាល់ដៃនូវ អនុស្សរណៈអន្តរការិយាល័យ មួយជូនអ្នកសម្របសម្រួល UNAKRT ទាក់ទងនឹងការរីកចម្រើននៃសំណុំរឿង ០០៤/២ ("អនុស្ស

---

ខែមករា ឆ្នាំ២០២០ ("អនុស្សរណៈ ចុះថ្ងៃទី១២ ខែមករា")។ សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែ មករា បានទទួលស្គាល់ការទទួលបានឯកសារនានាដែលភាគីបានបញ្ជូនទៅ អ.ជ.ស.ដ។

[12] *សូមមើល* សារអេឡិចត្រូនិក ផ្ញើជូនចៅក្រម អ.ជ.ស.ដ ពី Göran Sluiter នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៣:៣៣ រសៀល *(ភ្ជាប់ជាឧបសម្ព័ន្ធ គ)*។ ភ្ជាប់នឹងសារអេឡិចត្រូនិកនេះ គឺលិខិតមួយ ពីសហមេធាវីការពារក្ដី ជូនចំពោះចៅក្រម អ.ជ.ស.ដ, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ *(ភ្ជាប់ជាឧបសម្ព័ន្ធ P1 (អង់គ្លេស) និង P2 (ខ្មែរ))*។ *សូមមើលផងដែរ* ឯកសារ **D359/36.2 & D360/45.2** សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ទទួលស្គាល់ការទទួលបាន ឯកសារនានាដែលបានផ្ញើពីភាគី ទៅ អ.ជ.ស.ដ។

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ទាក់ទងនឹងការប្ដឹងឲ្យទទួលយកសំណុំរឿង ០០៤/២, ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធ Q1 (អង់គ្លេស) និង Q2 (ខ្មែរ))*។ *សូមមើលផងដែរ* ឯកសារ **D359/36.2 & D360/45.2** សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ទទួលស្គាល់ការទទួលបាន ឯកសារនានាដែលបានផ្ញើពីភាគី ទៅ អ.ជ.ស.ដ។

[14] ការដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ព្រះរាជអាជ្ញាអន្តរជាតិ ជាមួយឧបសម្ព័ន្ធ ក សម្ងាត់ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធ R1 (អង់គ្លេស) និង R2 (ខ្មែរ))*។ *សូមមើលផងដែរ* ឯកសារ **D359/36.2 & D360/45.2** សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា។

រណៈ ចុះថ្ងៃទី១៥ ខែមករា របស់ ស.ព.អ")[15]។ ក្នុងអនុស្សរណៈនេះ ស.ព.អ បានបញ្ជាក់អំពីកង្វល់របស់ខ្លួនថា គ្មានសារណាណាមួយនៃសារណារបស់ខ្លួនដែលបានដាក់ជាមួយ អ.ជ.ស.ដ ត្រូវបានជូនដំណឹងទៅភាគីឡើយ ហើយ ស.ព.អ ក៏បានស្នើឲ្យការិយាល័យរដ្ឋបាល ("OA") ពិចារណា និងអនុវត្តវិធានការនានាតាមដែលខ្លួនអាចធ្វើបាន ធ្វើយ៉ាងណាឲ្យដំណើរការអាចធ្វើដំណើរទៅមុខបានខាងផ្នែករដ្ឋបាល និង/ឬ ដោះស្រាយកុំឲ្យមានការពន្យារពេល។

11. ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ អោ អាន បានដាក់សេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់គាត់ តាមរយៈសារអេឡិចត្រូនិកមួយ ជូន អ.ជ.ស.ដ[16]។

12. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ដ បានបញ្ជូនសារអេឡិចត្រូនិកមួយក្នុងនាម អ.ជ.ស.ដ ជូនគូភាគីដោយបានថ្លែងថា សេចក្តីពិចារណារបស់ អ.ប.ជ មិនបានជូនដំណឹងទៅ អ.ជ.ស.ដ ទេ ហើយទាំងសំណុំរឿង និងទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏មិនទាន់បានបញ្ជូនទៅឡើយដែរ[17]។ ស.ព.អ និង អោ អាន បានដាក់សារណាជាលាយលក្ខណ៍ជាច្រើនជាបន្តបន្ទាប់ទៅ អ.ប.ជ ទាក់ទងនឹងដំណាក់កាលរដ្ឋបាលទាំងអស់នេះ ដោយដាក់ជាសាធារណៈទាំងអស់[18]។

---

[15] អនុស្សរណៈអន្តរការិយាល័យ មានចំណងជើងថា "ការរីកចម្រើននៃសំណុំរឿង ០០៤/២ អោ អាន" ពី ស.ព.អ លោកស្រី Brenda J. Hollis ជូនអ្នកសម្របសម្រួល UNAKRT លោក Knut Rosandhaug, ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។ *ភ្ជាប់ជាឧបសម្ព័ន្ធ ដ*។

[16] *សូមមើល* សារអេឡិចត្រូនិក ផ្ញើជូន អ.ជ.ស.ដ ពី Kristin Rosella នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៥:០៩ រសៀល *(ភ្ជាប់ជាឧបសម្ព័ន្ធ ឃ)* ដោយភ្ជាប់សេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធ S1 (អង់គ្លេស))*។ ដោយបានចម្លងជូន អ.ជ.ស.ដ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ *សូមមើលផងដែរ* ឯកសារ **D359/36.2 & D360/45.2** សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ទទួលស្គាល់ការទទួលបានឯកសារនានាដែលបានផ្ញើពីភាគី ទៅ អ.ជ.ស.ដ។

[17] ឯកសារ **D359/36.2 & D360/45.2** សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា។ សារអេឡិចត្រូនិកនេះ បានផ្ញើមកឲ្យសហព្រះរាជអាជ្ញា សហមេធាវី អោ អាន ចៅក្រម អ.ប.ជ និងប្រធាន និងអនុប្រធានរដ្ឋបាល។

[18] ឯកសារ **D359/25 & D360/34** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/26 & D360/35** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/27 & D360/36** សំណើ [របស់ អោ អាន] សុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ, ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/28 & D360/37** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៣

13. នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ការិយាល័យរដ្ឋបាលបានឆ្លើយតបទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១៥ ខែមករា របស់ ស.ព.អ[19]។ ចម្លើយតបនេះបានពន្យល់ថា ការិយាល័យរដ្ឋបាលអាចអនុវត្តកិច្ចរបស់តុលាការបានលើកលែងតែមាន ការណែនាំ ឬសេចក្តីបង្គាប់ពីអង្គជំនុំជម្រះ ដែលបានប្រាស្រ័យទាក់ទងតាមក្រឡាបញ្ជីរបស់អង្គជំនុំ ជម្រះនោះតែប៉ុណ្ណោះ។ ដូច្នេះ ការិយាល័យរដ្ឋបាលបាន "បំពេញកិច្ចការរបស់ខ្លួនយ៉ាងត្រឹមត្រូវសព្វគ្រប់ហើយ ទាក់ ទងនឹងបរិបទនេះ"។

14. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ អោ អាន បានដាក់បញ្ជីសាក្សី និងអ្នកជំនាញរបស់ខ្លួន និងចម្លើយតបទៅនឹងបញ្ជីរបស់ ស.ព.អ ជាសំណៅរឹងជាមួយ អ.ជ.ស.ដ ព្រមទាំងបានផ្តល់សំណៅចម្លងតាមសារអេឡិចត្រូនិក[20]។ គាត់បានធ្វើតាមនីតិវិធីរបស់គាត់ដូច្នេះម្តងហើយម្តងទៀតចំពោះការដាក់ឯកសារជាបន្តបន្ទាប់មកទៀតជូន អ.ជ.ស.ដ។

15. ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ អង្គភាពបណ្ណសារនៃការិយាល័យរដ្ឋបាល ("RAU") បានទទួលសេចក្តីណែនាំផ្ទុយគ្នាពីក្រឡាបញ្ជី អ.ប.ជ ទាក់ទងនឹងសំណុំរឿង ០០៤/២។ ក្រឡាបញ្ជី ម្នាក់បានដាក់ទម្រង់បែបបទមួយ ណែនាំឲ្យអង្គភាព RAU ជូនដំណឹងអំពីសេចក្តីពិចារណារបស់ អ.ប.ជ ទៅ អ.ជ.ស.ដ[21] ចំណែកក្រឡាបញ្ជីម្នាក់ទៀតបានផ្ញើសារអេឡិចត្រូនិក មកអង្គភាព RAU ដោយបានណែនាំ *មិនឲ្យ* ជូនដំណឹង អ.ជ.ស.ដ និងផ្ញើបណ្ណសារសំណុំរឿងនេះទេ[22]។

---

ខែមីនា ឆ្នាំ២០២០។ ឯកសារ **D359/30 & D360/39** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង០០៤/២ទុកក្នុងបណ្ណសារ, ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។ ឯកសារ **D359/31 & D360/40** ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ, ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[19] អនុស្សរណៈអន្តរការិយាល័យ មានចំណងជើងថា "សំណុំរឿង ០០៤/២" ពីអនុប្រធានការិយាល័យរដ្ឋបាល Knut Rosandhaug ជូនចំពោះ ស.ព.អ Brenda Hollis, ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០។ *ភ្ជាប់ជាឧបសម្ព័ន្ធ ថ*។

[20] សារណាស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ អោ អាន អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធ ១ សម្ងាត់ និងចម្លើយតបរបស់គាត់ទៅនឹងសារណាស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។ *ភ្ជាប់ជាឧបសម្ព័ន្ធ ទ។ សូមមើលផងដែរ* សារអេឡិចត្រូនិក ពី Kristin Rosella ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០, វេលាម៉ោង ៣:៤៨ រសៀល *(ភ្ជាប់ជាឧបសម្ព័ន្ធ ង)*។

[21] ឯកសារ **D359/36.4 & D360/45.4** ឯកសារភ្ជាប់ទី៤ ទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា ("សេចក្តីណែនាំអំពីការដាក់ឯកសារ"), ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

[22] ឯកសារ **D359/36.3 & D360/45.3** ឯកសារភ្ជាប់ទី៣ ទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា ("សេចក្តីណែនាំអំពីការដាក់ឯកសារ D359_24 និង D360_33.pdf"), ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

16. នៅថ្ងៃបន្ទាប់ ប្រធាន អ.ប.ជ ចៅក្រម ប្រាក់ គឹមសាន បានផ្ញើអនុស្សរណៈផ្ទៃក្នុងមួយ ជូនប្រធានផ្នែកគ្រប់គ្រងតុលាការ ("CMS") ដោយចម្លងជូនចៅក្រម អ.ប.ជ ផ្សេងទៀត ព្រមទាំងប្រធានការិយាល័យរដ្ឋបាលស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាលផង។ អនុស្សរណៈនេះថែងថា មតិយោបល់ និងសេចក្តីសម្រេចផ្ទាល់ខ្លួនរបស់ចៅក្រមម្នាក់ៗ មិនត្រូវមានអនុភាពក្នុងការអនុវត្តទេ" ហើយ "ការជូនដំណឹងទៅកាន់បុគ្គលណាម្នាក់ ឬអង្គជំនុំជម្រះណាមួយ ដែលមិនមែនជាភាគីនៃរឿងក្តីនេះ គឺជាការរំលោភសេចក្តីសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ"[23]។

17. នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ នេះផងដែរ ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានផ្ញើអនុស្សរណៈអន្តរការិយាល័យមួយជូនប្រធានការិយាល័យរដ្ឋបាលស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងប្រធាន CMS ដោយចម្លងជូនប្រធាន អ.ប.ជ និងចៅក្រមជាតិផ្សេងទៀត។ អនុស្សរណៈនេះលើកអំពីច្បាប់ពាក់ព័ន្ធ ទាក់ទងនឹងសេចក្តីពិចារណារបស់ អ.ប.ជ និងបានកត់សំគាល់ថា អំណាចរបស់ប្រធាន អ.ប.ជ អនុលោមតាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង មិនបានផ្តល់សិទ្ធិអំណាចឲ្យគាត់ណែនាំទៅ CMS ទេ - តាមពិតការធ្វើដូច្នេះ គឺជាការទំនាស់ដោយផ្ទាល់ជាមួយនឹងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង[24]។ ចៅក្រមអន្តរជាតិនៃ អ.ប.ជ នៅតែប្រកាន់ជំហរថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបទេ អាស្រ័យហេតុនេះ វានៅមានសុពលភាពដដែល ហើយ អ.ជ.ស.ដ ត្រូវបានប្តឹងឲ្យទទួលយកសំណុំរឿង ០០៤/២ នេះ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង និងថា ខាងរដ្ឋបាលពេលនេះត្រូវបានណែនាំឲ្យជូនដំណឹងទៅ អ.ជ.ស.ដ អំពីសេចក្តីពិចារណារបស់ អ.ប.ជ[25]។

---

[23] ឯកសារ **D359/36.5 & D360/45.5** ឯកសារភ្ជាប់ទី៥ ទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា ("សេចក្តីបញ្ជាក់បំភ្លឺអំពីសេចក្តីសម្រេចក្នុងសំណុំរឿង ០០៤/២"), ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០, ទំព័រ ២។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ អនុស្សរណៈបញ្ជាក់បំភ្លឺនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ជាឯកសារសាធារណៈ។ *សូមមើល* ឯកសារ **D359/34 & D360/43** អនុស្សរណៈរបស់លោកប្រធាន ទាក់ទងនឹងការជូនដំណឹងនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២, ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ("អនុស្សរណៈរបស់ប្រធាន អ.ប.ជ ចុះថ្ងៃទី២៩ ខែមករា")។

[24] ឯកសារ **D359/36.6 & D360/45.6** ឯកសារភ្ជាប់ទី៦ ទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា ("ការជូនដំណឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២"), ទំព័រ១-៣ (ច្បាប់), ទំព័រ ៥ (អំណាចរបស់ប្រធាន អ.ប.ជ)*យោង* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៤(១), ច្បាប់ អ.វ.ត.ក មាត្រា ១២, វិធានផ្ទៃក្នុង ៧៧(១៣)។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ អនុស្សរណៈនៃការជូនដំណឹងនេះ ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ជាឯកសារសាធារណៈ។ *សូមមើល* ឯកសារ **D359/35 & D360/44** អនុស្សរណៈរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ទាក់ទងនឹងការជូនដំណឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២, ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ("អនុស្សរណៈរបស់ចៅក្រមអន្តរជាតិនៃ អ.ប.ជ ចុះថ្ងៃទី២៩ ខែមករា")។

[25] ឯកសារ **D359/35 & D360/44** អនុស្សរណៈរបស់ចៅក្រមអន្តរជាតិនៃ អ.ប.ជ ចុះថ្ងៃទី២៩ ខែមករា, ទំព័រ ៥-៦។

18. ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ប្រធានការិយាល័យរដ្ឋបាលស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល បានផ្ញើអនុស្សរណៈអន្តរការិយាល័យមួយជូនប្រធាន អ.ប.ជ (ដោយបានចម្លងជូនទៅក្រុម អ.ប.ជ ផ្សេងទៀត) ដោយបានស្នើឲ្យមាន "ការបញ្ជាក់អំពីសិទ្ធិអំណាច" លើរបៀបដែលអង្គភាព RAU គួរអនុវត្តចំពោះសេចក្តីណែនាំដែលផ្ទុយគ្នាពីក្រឡាបញ្ជី អ.ប.ជ ទាំងពីរ ឬតាមជម្រើសផ្សេង គឺការណែនាំដែលអាចអនុវត្តបាន[26]។

19. ដោយមិនបានដឹងថា សកម្មភាពទាំងឡាយដូចបានរៀបរាប់ក្នុងកថាខណ្ឌ ១៥-១៨ ខាងលើបានកើតឡើង ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ស.ព.អ បានដាក់សំណើមួយ ដោយបានស្នើឲ្យ អ.ជ.ស.ដ ស្នើទៅ អ.ប.ជ ឲ្យចាត់វិធានការរដ្ឋបាលចាំបាច់នានាទាំងអស់ ដើម្បីធ្វើយ៉ាងណាឲ្យមានការចាត់បញ្ជូនជាបន្ទាន់នូវដីកាបញ្ជូនរឿងទៅជំនុំជម្រះនិងសំណុំរឿងដែលនៅសេសសល់[27]។

20. នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ ស.ព.អ បានបញ្ជូនអនុស្សរណៈអន្តរការិយាល័យមួយទៅ ការិយាល័យរដ្ឋបាល ដោយបានស្នើឲ្យការិយាល័យរដ្ឋបាលចាត់វិធានការជាបន្ទាន់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ ទៅ អ.ជ.ស.ដ ដើម្បីអនុវត្តតាមសេចក្តីពិចារណារបស់ អ.ប.ជ និងវិធានផ្ទៃក្នុង[28]។ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ការិយាល័យរដ្ឋបាលបានឆ្លើយតបដោយថ្លែងថា ខ្លួនអនុវត្តកិច្ចរបស់

---

[26] ឯកសារ **D359/36.7 & D360/45.7** ឯកសារភ្ជាប់ទី៧ ទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា ("សំណើសុំបញ្ជាក់បំភ្លឺអនុលោមតាមវិធាន ១០(២)"), ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

[27] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការដើម្បីទទួលបានសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ (អោ អាន) និងសំណុំរឿង, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធ U1 (អង់គ្លេស) និង U2 (ខ្មែរ))*។ *សូមមើលផងដែរ* ឯកសារ **D359/36.8 & D360/45.8** ឯកសារភ្ជាប់ទី៨ ទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា (សារអេឡិចត្រូនិក មានចំណងជើងថា "ពាក់ព័ន្ធនឹងសំណើរបស់ ស.ព.អ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០") ដែលបានបញ្ជូនដោយក្រឡាបញ្ជី និងមន្ត្រីច្បាប់ អ.ជ.ស.ដ ស៊ុយ ហុងលីម ក្នុងនាម អ.ជ.ស.ដ, ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ("សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី១០ ខែកុម្ភៈ"), វេលាម៉ោង ១១:៤៤ ព្រឹក ដោយបានទទួលស្គាល់ការទទួលបាននូវសំណើរបស់ ស.ព.អ។

[28] អនុស្សរណៈអន្តរការិយាល័យ មានចំណងជើងថា "សំណើសុំវិធានការរដ្ឋបាល ដើម្បីអនុវត្តសំណុំរឿង ០០៤/២, ឯកសារ D359/24 & D360/33, សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណា") ពី ស.ព.អ Brenda J. Hollis ជូនប្រធានការិយាល័យរដ្ឋបាលស្តីទី តូនី ក្រាញ់ និង អនុប្រធានការិយាល័យរដ្ឋបាល Knut Rosandhaug, ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០។ *ភ្ជាប់ជាឧបសម្ព័ន្ធ ខ*។

តុលាការបានលើកលែងតែមានការណែនាំ ឬសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលពាក់ព័ន្ធប៉ុណ្ណោះ[29]។

21. ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ នេះដែរ អ្វីដែលហាក់ដូចជាផ្ទុយគ្នាទៅនឹងការជូនដំណឹងជាផ្លូវការ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អំពីសេចក្ដីពិចារណារបស់ អ.ប.ជ តាមសារអេឡិចត្រូនិកទៅចៅក្រម អ.ជ.ស.ដ ពីររូប និងក្រឡាបញ្ជីនោះ[30] ក្រឡាញបញ្ជី អ.ជ.ស.ដ បានជូនដំណឹងទៅភាគីតាមសារអេឡិចត្រូនិកថា ទោះបីជា អ.ជ.ស.ដ បានដឹងអំពីសេចក្ដីពិចារណារបស់ អ.ប.ជ ដែលគេអាចរកបានជាសាធារណៈក៏ដោយ តែខ្លួននៅមិនទាន់ត្រូវ*បានជូនដំណឹងជាផ្លូវការណ៍* ដោយ អ.ប.ជ អំពីសេចក្ដីពិចារណានោះនៅឡើយហើយសំណុំរឿងក៏មិនទាន់បានបញ្ជូនមកខ្លួន។ សារអេឡិចត្រូនិកនេះបានបញ្ចប់ថា អ.ប.ជ ត្រូវតែផ្ដួចផ្ដើមសកម្មភាពទាំងនោះ[31]។

22. ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស.ព.អ បានដាក់សំណើមួយសុំឲ្យ អ.ជ.ស.ដ បញ្ជាក់បំភ្លឺចំពោះសារអេឡិចត្រូនិក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ និងសុំឲ្យការដាក់ឯកសារនៃសំណុំរឿង០០៤/២ ទៅជាសាធារណៈដែល អ.ជ.ស.ដ អាចរកបាន ដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធី[32]។ ក្នុងសំណើរបស់ខ្លួន ស.ព.អ បានសួរថាតើ កិច្ចដែលធ្លាប់តែគ្រប់គ្រាន់ដើម្បីជូនដំណឹងទៅ អ.ជ.ស.ដ និងការបញ្ជូនសំណុំរឿង ០០១ និង ០០២ បែជាមិនអាចពន្យល់បានថាវាលែងគ្រប់គ្រាន់សម្រាប់សំណុំរឿង ០០៤/២ ទៅវិញ[33]។ មកទល់ថ្ងៃនេះ គ្មានការបំភ្លឺពី អ.ជ.ស.ដ លើសំណួរនេះទេ។

---

[29] អនុស្សរណៈអន្តរការិយាល័យ មានចំណងជើងថា "អនុស្សរណៈ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ ទាក់ទងនឹងសំណុំរឿង ០០៤/២" ពីលោក តូនី ក្រាញ់ ប្រធានការិយាល័យរដ្ឋបាលស្ដីទី និងលោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល, ជូន ស.ព.អ Brenda J. Hollis ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។ *ភ្ជាប់ជាឧបសម្ព័ន្ធ ឍ។*

[30] ស.ព.អ យល់ថា ចៅក្រមជាតិនៃ អ.ជ.ស.ដ មិនត្រូវបានជូនដំណឹងអំពីសេចក្ដីពិចារណារបស់ អ.ប.ជ ទេ ដោយសារនៅពេលចេញសេចក្ដីពិចារណានេះ ចៅក្រមជាតិនៃ អ.ជ.ស.ដ មិនមានកិច្ចសន្យាការងារជាមួយ អ.វ.ត.ក។

[31] ឯកសារ **D359/36.8 & D360/45.8** សារអេឡិចត្រូនិករបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី១០ ខែកុម្ភៈ (ចម្លងជូនចៅក្រមជាតិនៃ អ.ប.ជ ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល)។

[32] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំការបញ្ជាក់បំភ្លឺអំពីសារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (ជាមួយឧបសម្ព័ន្ធ ក-ច សាធារណៈ), ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ("សំណើសុំការបញ្ជាក់បំភ្លឺរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជូន អ.ជ.ស.ដ")។ *(ភ្ជាប់ជា ឧបសម្ព័ន្ធ V1 (អង់គ្លេស) និង V2 (ខ្មែរ))*។

[33] សំណើសុំការបញ្ជាក់បំភ្លឺរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជូន អ.ជ.ស.ដ, កថាខណ្ឌ ២១-២៦។

23. នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ ស.ព.អ បានទទួលសំណៅបកប្រែជាភាសាខ្មែរនៃសេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន តាមរយៈសារអេឡិចត្រូនិក[34]។ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួនជាមួយ អ.ជ.ស.ជ[35]។

24. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញា សហមេធាវី អោ អាន និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានទទួលតាមរយៈសារអេឡិចត្រូនិក នូវអនុស្សរណៈអន្តរការិយាល័យមួយពីថៅក្រមអន្តរជាតិនៃ អ.ប.ជ មានចំណងជើងថា "ការបញ្ជូនសំណុំរឿង ០០៤/២" ("អនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា")[36]។ អនុស្សរណៈនេះ និងឯកសារភ្ជាប់ទាំងប្រាំបីរបស់វា បានរៀបរាប់យ៉ាងលម្អិតអំពីការជាប់គាំងរបស់តុលាការ និងផ្នែករដ្ឋបាលដែលបានកើតឡើងនៅក្នុង អ.ប.ជ និង OA ដែលគូភាគីមិនធ្លាប់បានដឹងពីមុនមក និងដូចបានរៀបរាប់ដោយសង្ខេបក្នុងកថាខណ្ឌ ១៥-១៨ ខាងលើ។ ថៅក្រមជាតិនៃ អ.ប.ជ និងក្រឡាបញ្ជី អ.ជ.ស.ជ ក៏បានទទួលសំណៅចម្លងនៃអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា និងឯកសារភ្ជាប់របស់វានេះផងដែរ។

25. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធាន អ.ប.ជ បានចេញអនុស្សរណៈមួយ ("អនុស្សរណៈ ចុះថ្ងៃទី ១៦ ខែមីនា") ជូនមកសហព្រះរាជអាជ្ញា សហមេធាវី អោ អាន និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ អនុស្សរណៈនេះ ដែលបានចេញ "ក្នុងនាមប្រធាន អ.ប.ជ" បានបញ្ជាក់យ៉ាងច្បាស់ថា តាមការប៉ាន់ស្មានរបស់គាត់ អ.ប.ជ បាន "បំពេញភារកិច្ចរបស់ខ្លួនរួចរាល់ហើយ" និងមិនតម្រូវឱ្យបំពេញកិច្ចរដ្ឋបាលណាមួយបន្ថែមទៀតឡើយ[37]។

26. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ស.ព.អ បានស្នើឱ្យដាក់បញ្ចូលអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា ឯកសារភ្ជាប់ទាំងប្រាំបីនៃអនុស្សរណៈនេះ និងអនុស្សរណៈ ចុះថ្ងៃទី១៦ ខែមីនា ទៅក្នុងសំណុំរឿង

---

[34] *សូមមើល* សារអេឡិចត្រូនិក ពី Kristin Rosella មានចំណងជើងថា "សំណៅចម្លងនៃសំណៅបកប្រែជាភាសាខ្មែរនៃសេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន", ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០, វេលាម៉ោង ៤:៣៣ រសៀល។ *ភ្ជាប់ជាឧបសម្ព័ន្ធ ច (សារអេឡិចត្រូនិក), ឧបសម្ព័ន្ធ S2 (សំណៅបកប្រែនៃសេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន)*។

[35] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០។ *(ភ្ជាប់ជា ឧបសម្ព័ន្ធ W1 (អង់គ្លេស) និង W2 (ខ្មែរ))*។

[36] ឯកសារ **D359/36 & D360/45** អនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា។

[37] ឯកសារ **D359/37 & D360/46** អនុស្សរណៈរបស់ប្រធាន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០, ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈ ចុះថ្ងៃទី១៦ ខែមីនា"), កថាខណ្ឌ ៥។

០០៤/២ និងធ្វើឲ្យទៅជាសាធារណៈ[38]។ ឯកសារដែលបានស្នើឡើងទាំងនេះ ក្រោយមកត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងជាឯកសារសាធារណៈ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០[39]។

27. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០៤/២ ចំនួនប្រាំបីនាក់ បានដាក់សំណើមួយទៅ អ.ប.ជ ដោយរៀបរាប់យ៉ាងលម្អិតអំពីការរំលោភ និងការមិនគោរពយ៉ាងធ្ងន់ធ្ងរម្ដងហើយម្ដងទៀតចំពោះសិទ្ធិរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបាននូវតម្លាភាព ភាពប្រាកដប្រជាខាងផ្លូវច្បាប់ ការចូលរួម និងការប្រព្រឹត្តិចំពោះដោយត្រឹមត្រូវយុត្តិធម៌ និងដោយមានតុល្យភាពនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២[40]។ សំណើនេះសុំឲ្យ អ.ប.ជ ការពារសិទ្ធិទាំងនេះតាមរយៈការចាប់យកនូវវិធានការឧបាស្រ័យជាក់លាក់នានា ហើយបានអះអាងថា អ.វ.ត.ក ត្រូវតែតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងពន្លឿនសំណុំរឿងនេះឲ្យបានទៅដល់ អ.ជ.ស.ដ ដោយសារតែគ្មានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដើម្បីបដិសេធលើរឿងក្ដីនេះ។ មកទល់ថ្ងៃនេះ អ.ប.ជ មិនបានដោះស្រាយចំពោះសំណើនេះទេ។

28. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ នេះផងដែរ ជាលទ្ធផលដោយផ្ទាល់ដែលកើតចេញពីសញ្ញាបង្ហាញមួយរបស់ អ.ប.ជ ដែលថា អ.ប.ជ នឹងមិនចាត់ការអ្វីបន្ថែមទៀតនៅក្នុងសំណុំរឿង ០០៤/២[41]នោះ ស.ព.អ បានធ្វើសំណើរបស់ខ្លួនសាជាថ្មីសុំឲ្យ អ.ជ.ស.ដ ធ្វើឲ្យមានការរីកចម្រើនទៅលើសំណុំរឿង ០០៤/២ ទៅកាន់សវនាការជំនុំជម្រះ[42]។ អោ អាន បានឆ្លើយតបនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ថា

---

[38] ឯកសារ **D359/32 & D360/41** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បន្ថែមអនុស្សរណៈរបស់ អ.ប.ជ ចុះថ្ងៃទី១២ និង ទី១៦ ខែមីនា ទៅក្នុងសំណុំរឿង ០០៤/២, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០, កថាខណ្ឌ ៦។

[39] *សូមមើល* ឯកសារ **D359/36 & D360/45** អនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា។ ឯកសារ **D359/36.1-D359/36.8 & D360/45.1-D360/45.8** ឯកសារភ្ជាប់ទី៨ ទៅនឹងអនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា។ ឯកសារ **D359/37 & D360/46** អនុស្សរណៈ ចុះថ្ងៃទី១៦ ខែមីនា។

[40] ឯកសារ **D359/33 & D360/42** សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានារបស់អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២, ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ("សំណើសុំការពារសិទ្ធិរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី")។

[41] *សូមមើល* ឯកសារ **D359/36 & D360/45** អនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា, កថាខណ្ឌ ៣៤-៣៧។ ឯកសារ **D359/37 & D360/46** អនុស្សរណៈ ចុះថ្ងៃទី១៦ ខែមីនា, កថាខណ្ឌ ៥។

[42] សំណើសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យអង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការចាំបាច់នានាដើម្បីពន្លឿនសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ រួមទាំងការបង្គាប់ឲ្យមានការបញ្ជូនជាបន្ទាន់នូវសំណុំរឿង ០០៤/២ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធ X1 (អង់គ្លេស) និង X2 (ខ្មែរ)*។

គាត់មិនបានពិចារណាថា អ.ជ.ស.ដ ត្រូវបានប្ដឹងដោយស្របច្បាប់អំពីសំណុំរឿង ០០៤/២ នេះទេ ហើយអះអាងថា អ.ជ.ស.ដ កង្វះយុត្តាធិការដើម្បីអនុវត្តសំណើសាថ្មីរបស់ ស.ព.អ[43]។

29. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ក្រឡាបញ្ជី អ.ជ.ស.ដ បានផ្ញើតាមសារអេឡិចត្រូនិកនូវ សេចក្ដីថ្លែងការណ៍មកកាន់គូភាគី ("សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា")[44] ដែលបានផ្សព្វផ្សាយជាសាធារណៈផងដែរនៅលើគេហទំព័រ អ.វ.ត.ក[45]។ ចៅក្រម អ.ជ.ស.ដ បានថ្លែងថា ការចេញសេចក្ដីសម្រេចផ្លូវការណ៍ "មិនអាចធ្វើបានទេ" ហើយចៅក្រមបានចោទថា សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា គ្មានអំណាចផ្លូវច្បាប់ឡើយ សេចក្ដីថ្លែងការណ៍បានចេញរួមគ្នាដោយសង្ឃឹមថា វានឹងផ្ដល់នូវតម្លាភាព និងភាពច្បាស់លាស់ដល់សាធារណជន និងភាគី[46]។ ចៅក្រមអន្តរជាតិនៃ អ.ជ.ស.ដ បានបង្ហាញលើជំនឿមួយថា "អំណះអំណាងមួយអាចនឹងធ្វើបាន នៅក្រោមកាលៈទេសៈពិសេសប្លែកពីគេនៃរឿងក្ដីនេះ គឺអង្គជំនុំជម្រះមាន*សិទ្ធិអំណាចជាប់មកជាមួយ* ដើម្បីដោះស្រាយលើបញ្ហាចំបងខ្លះដែលបានលើកឡើងដោយភាគី" ប៉ុន្តែចៅក្រមជាតិបានអះអាងថា អ.ជ.ស.ដ គ្មានសំណុំរឿងនេះទេ ពួកគាត់ជឿថា រឿងនេះបានបិទបញ្ចប់នៅចំពោះមុខ អ.ប.ជ រួចហើយ ហើយ អ.ជ.ស.ដ គ្មានសិទ្ធិអំណាចដើម្បីធ្វើសេចក្ដីសម្រេច*ណាមួយ* ទាក់ទងនឹងករណីនេះទេ[47]។ ភាគីទទួលបានការជូនដំណឹងថា ឯកសារពាក់ព័ន្ធ និងសំណើដែលភាគីបានដាក់ទៅ អ.ជ.ស.ដ

---

[43] *សូមមើល* ចម្លើយតបទៅនឹងសំណើសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការចាំបាច់នានាដើម្បីពន្លឿនសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ រួមទាំងការបង្គាប់ឱ្យមានការបញ្ជូនជាបន្ទាន់នូវសំណុំរឿង ០០៤/២ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ *(ភ្ជាប់ជាឧបសម្ព័ន្ធ Y1 (អង់គ្លេស) និង Y2 (ខ្មែរ)* ដែលបានភ្ជាប់ទៅនឹងសារអេឡិចត្រូនិកដែលបានផ្ញើទៅកាន់ចៅក្រម អ.ជ.ស.ដ ចេញពី Kristin Rosella នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ៦:១០ ល្ងាច *(ភ្ជាប់ជាឧបសម្ព័ន្ធ ឆ)*។

[44] សេចក្ដីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ទាក់ទងសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ("សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា") *(ភ្ជាប់ជាប្រភពឯកសារយោង ១៦ក (អង់គ្លេស) និង ១៦ខ (ខ្មែរ))*។ សេចក្ដីថ្លែងការណ៍នេះ បានភ្ជាប់ទៅនឹងសារអេឡិចត្រូនិកពីក្រឡាបញ្ជី អ.ជ.ស.ដ លឹម ស៊ុយហុង មានចំណងជើងថា "សេចក្ដីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១:៤៩ រសៀល *(ភ្ជាប់ជាឧបសម្ព័ន្ធ ជ)*។

[45] អាចរកបានជាភាសាអង់គ្លេសនៅក្នុង https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao (ការចូលពិនិត្យចុងក្រោយនៅថ្ងៃដែលឯកសារនេះបានដាក់)។

[46] សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រ ២។

[47] សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រ ២។

នឹងត្រូវបានបង្វិលត្រឡប់វិញ ហើយចៅក្រមជាតិបានប្រកាសយ៉ាងច្បាស់ដោយគ្មានមន្ទិលសង្ស័យថា "គ្មានការជំនុំជម្រះលើ អោ អាន ទេនៅពេលនេះ ឬ នៅពេលអនាគត"[48]។

30. នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ ឯកសារសំណុំរឿង ០០៤/២ ដែល ស.ព.អ បានដាក់ជាសំណៅរឹងទៅ អ.ជ.ស.ដ ត្រូវបានបង្វិលត្រឡប់មក ស.ព.អ វិញ ដែលដាក់ពាក្យសំគាល់ថា "បង្វិលត្រឡប់ទៅអ្នកផ្ញើ ៩-៤-២០២០"[49]។

## II. ច្បាប់ជាធរមាន

### ក. ភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខ

31. វិធាន ១០៤(៤)(ក) ចែងថា សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ "ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" ស្ថិតក្រោមការប្ដឹងសាទុក្ខភ្លាមៗទៅកាន់ អ.ជ.ត.ក។ បណ្ដឹងសាទុក្ខភ្លាមៗត្រូវតែដាក់ក្នុងរយៈពេល ៣០ថ្ងៃ នៃកាលបរិច្ឆេទរបស់សេចក្ដីសម្រេច ឬសេចក្ដីជូនដំណឹងដែលរងការជំទាស់[50]។

32. វិធាន២១(១) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

---

[48] សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រ ២។

[49] សារអេឡិចត្រូនិក ពីលោក គួច វណ្ណារិទ្ធិ ជូនចំពោះ ក.ស.ព មានចំណងជើងថា "ឯកសារដែលបានដាក់ជាសំណៅរឹង ទៅ អ.ជ.ស.ដ សំណុំរឿង ០០៤/២ ត្រូវបានបង្វិលត្រឡប់មក ក.ស.ព វិញ នៅរសៀលនេះ", ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០, វេលាម៉ោង ១:៥៩ រសៀល (*ភ្ជាប់ជាឧបសម្ព័ន្ធ I*)។ "ការបង្វិលត្រឡប់ទៅអ្នកផ្ញើ" នៃការទទួលឯកសារដែលបានដាក់ពី អ.ជ.ស.ដ ទៅ ស.ព.អ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ (*ភ្ជាប់ជាឧបសម្ព័ន្ធ J*)។

[50] វិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ [...]។

គ-អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី [...]។

## ខ. បទដ្ឋាននៃបណ្តឹងសាទុក្ខ

33. វិធាន ១០៤(១) ចែងថា អ.ជ.ត.ក ត្រូវសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ អ.ជ.ស.ដ នៅពេលដែលមាន ក) កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈសេចក្តីសម្រេចនោះ។ ឬ ខ) កំហុសនៃអង្គហេតុ ដែលនាំអោយមានភាពមិនយុត្តិធម៌។ បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់ អ.ជ.ស.ដ ក៏ផ្អែកផងដែរលើកំហុសជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ ដែលបណ្តាលឲ្យមានព្យសនកម្មលើម្ចាស់បណ្តឹងសាទុក្ខ[51]។

## គ. ការរលត់កិច្ចដំណើរការនីតិវិធី អ.វ.ត.ក

34. វិធាន ២ ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធាននៃផ្ទៃក្នុងនេះ [...] អង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅតាមមាត្រា ១២ (១) នៃកិច្ចព្រមព្រៀង និង មាត្រា ២០ ថ្មី ២៣ ថ្មី ៣៣ ថ្មី ឬមាត្រា ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធាននៃផ្ទៃក្នុងនេះ និង ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។

35. មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

[51] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

នីតិវិធីត្រូវតែស្របជាមួយនឹងច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិគេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ[52]។

36. តាមច្បាប់កម្ពុជា៖

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ៖

១-មរណភាពនៃជនល្មើស។

២-ការផុតអាជ្ញាយុកាល។

៣-ការលើកលែងទោសទូទៅ។

៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ។

៥-អាជ្ញាអស់ជំនុំ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចធ្វើបានទៀតទេ ឬត្រូវតែបញ្ចប់[53]។

## ឃ. "គោលជំហរស្វ័យប្រវត្តិ" ដែលជាមូលដ្ឋាននៃក្របខណ្ឌច្បាប់ អ.វ.ត.ក

37. មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ [...] ប្រសិនបើគ្មានមតិភាគច្រើន

[52] ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី ពង្រឹងមាត្រា ១២(១) ដោយការផ្តល់នូវផ្នែកពាក់ព័ន្ធ៖ "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ត្រូវចោទ និងមាន ការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុង កម្រិតអន្តរជាតិ"។ *សូមមើលផងដែរ* ច្បាប់ អ.វ.ត.ក មាត្រា ៣៧ថ្មី ("ប្រការដែលបានចែងនៅក្នុងមាត្រា៣៣ ៣៤ និង ៣៥ ត្រូវអនុវត្ត *ដូចគ្នា* ចំពោះការជំនុំជម្រះក្តីនៅក្នុងជំនុំជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល")។

[53] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ ("CCCP") មាត្រា ៧។

ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្ដីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់ **ត្រូវ** ដំណើរការទៅមុខទៀត[54]។

38. វិធាន ៧៧(១៣) ចែងថា៖

សេចក្ដីសម្រេចរបស់ អង្គ[អង្គបុរេជំនុំជម្រះ] តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន) រូបយ៉ាងតិច។ សេចក្ដីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ **សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះ ត្រូវ**អនុវត្តដូចខាងក្រោម៖

ក-ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ។

ខ-ក្នុងករណីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ **អង្គបុរេជំនុំជម្រះត្រូវសម្រេចប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង** ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត[55]។

39. វិធាន ៧៩(១) ចែងថា៖

អង្គជំនុំជម្រះសាលាដំបូងទទួលបណ្ដឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

40. វិធាន ១(២) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង [...]។

## III. **សារណា**

---

[54] សង្កត់ន័យបន្ថែម។ *សូមមើលផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា៥(៤), ៦(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២០ថ្មី។

[55] សង្កត់ន័យបន្ថែម។

## ក. ភាពអាចទទួលយកបាន

### ១. បណ្តឹងសាទុក្ខនេះអាចទទួលយកបានអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង

41. វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចរបស់ អ.ជ.ស.ជ ដែលមានអានុភាពរំលុតកិច្ចដំណើរការនីតិវិធី គឺស្ថិតក្រោមការប្តឹងសាទុក្ខទៅកាន់ អ.ជ.ត.ក។ រាល់ទិដ្ឋភាពទាំងអស់នៃវិធាននេះត្រូវបានបំពេញដោយកាលៈទេសៈនានានៃសំណុំរឿងនេះ។ ទីមួយ ដូចដែលបានពិភាក្សាខាងក្រោមក្នុងផ្នែកអង្គសេចក្តីនៃបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយ៉ាងត្រឹមត្រូវតាមច្បាប់នូវសំណុំរឿង០០៤/២ នេះ[56] ដូច្នេះមានកិច្ចដំណើរការនីតិវិធីដែលត្រូវរំលត់[57]។

42. ទីពីរ ទោះបីជាការប្រកាសរបស់ អ.ជ.ស.ជ ថា "ការចេញសេចក្តីសម្រេចជាផ្លូវការ" មិនអាចធ្វើទៅបាន និងការរៀបរាប់មិនត្រឹមត្រូវរបស់ខ្លួនក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣ ខែមេសា ថាជា "សេចក្តីថ្លែងការណ៍រួម" ដែល "ពុំមានអានុភាពផ្លូវច្បាប់"[58] យ៉ាងណាក៏ដោយ ក៏ភាពនៅស្ងៀមរបស់ អ.ជ.ស.ជ[59] រួមផ្សំជាមួយនឹងសេចក្តីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា បង្កើតបានជាសេចក្តីសម្រេចមួយដែលអាចត្រូវប្តឹងសាទុក្ខទៅកាន់ អ.ជ.ត.ក បាន។ អ.ជ.ត.ក បានសម្រេចពីមុនថា អនុស្សរណៈរបស់ អ.ជ.ស.ជ បង្កើតបានជា "សេចក្តីសម្រេច" ពីព្រោះវាមាន "*ការបញ្ជាក់*ពីចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត ទោះបីមានកង្វះនូវទម្រង់ច្បាស់លាស់ក៏ដោយ"[60]។ អ.ជ.ត.ក ក៏បានរកឃើញថា "ការអនុវត្តចាកប្រាស់ពីទម្រង់ និងនិមិត្តសញ្ញារបស់តុលាការ

---

[56] *សូមមើល* ផ្នែក IV.ខ.១, *យោងខាងលើ*។

[57] សំណុំរឿង០០២-ឯកសារ **E306/7/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីជំទាស់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើវិសាលភាពនៃសំណុំរឿង ០០២ទាក់ទងការចោទពីបទរំលោភសេពសន្ថវៈ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ២៣។ អ.ជ.ត.ក កត់សម្គាល់ថា ការដោះស្រាយថាតើ មានកិច្ចដំណើរការនីតិវិធីរលត់ជាធរមាន ឬយ៉ាងណា គឺ "ជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងអង្គសេចក្តីនៃបណ្តឹងសាទុក្ខ" ហើយដូច្នេះវាភ្ជាប់បញ្ហានៃភាពអាចទទួលយកបាននេះទៅនឹងការពិចារណាលើអង្គសេចក្តី ដោយសារភាពអាចទទួលយកបាននឹងបង្ហាញថាតើ អង្គជំនុំជម្រះសាលាដំបូងទទួលការចោទប្រកាន់ផ្នែកអង្គហេតុអំពីការរំលោភសេពសន្ថវៈ ដែលកើតឡើងនៅក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំឬទេ។ ទោះជាយ៉ាងណា អ.ជ.ត.ក មិនដែលទទួលពិនិត្យបញ្ហានេះទេ ដោយសារខ្លួនបានសន្និដ្ឋានថាបណ្តឹងសាទុក្ខនោះខុសពេលវេលា។

[58] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២។

[59] ដូចដែលបានរៀបរាប់នៅក្នុងផ្នែកប្រវត្តិនីតិវិធី *ខាងលើ* ជាពិសេស កថាខណ្ឌ ២៩-៣០។

[60] សំណុំរឿង០០២-ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ("សេចក្តីសម្រេច អ.ជ.ត.ក លើវិសាលភាពក្នុងសំណុំរឿង ០០២/១") កថាខណ្ឌ ៣០។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលា

មិនបានចាត់ទុកសកម្មភាពនេះមោឃៈបានទេ" ផ្ទុយទៅវិញពួកវា "ត្រូវតែត្រួតពិនិត្យឡើងវិញ ទៅលើទិដ្ឋភាពយុត្តិធម៌ ភាពច្បាស់លាស់គ្រប់គ្រាន់ចំពោះអត្ថិភាព ខ្លឹមសារ និងផលវិបាកនៃកិច្ចដំណើរការនីតិវិធី"[61]។

43. តាមការវិភាគនេះ ការបរាជ័យរបស់ អ.ជ.ស.ដ ក្នុងការចាត់វិធានការណាមួយទាក់ទងនឹងសំណុំរឿង០០៤/២ រួមបញ្ចូលទាំងការអនុញ្ញាតឱ្យមានការដាក់ឯកសារ និងការជូនដំណឹងតាមអេឡិចត្រូនិក ត្រូវបានធ្វើឡើងជាច្រើនដង និងមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ហើយសេចក្តីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា នេះក៏បានបញ្ជាក់ច្បាស់ដូចគ្នាដែរថានឹងមិនមានអ្វីប្រែប្រួលទេ[62]។ ការបង្វែរត្រឡប់វិញរបស់ អ.ជ.ស.ដ នូវឯកសារសំណៅរឿងមកកាន់ភាគី ដោយមិនបានពិចារណាលើឯកសារទាំងនោះ គឺជាកិច្ចតាមផ្លូវតុលាការដាច់ខាតជាផ្លូវការដែលបានបង្ហាញបន្ថែមទៀតថា អ.ជ.ស.ដ នឹងមិនអនុវត្តយុត្តាធិការដើម្បីស្វែងយល់អំពីសារណាក្នុងសំណុំរឿង០០៤/២ ទេ កុំថាឡើងដោះស្រាយវានោះ[63]។ ចៅក្រមជាតិបានឈានហួសពីនេះដើម្បីបង្ហាញចេតនារបស់ខ្លួន។ ពួកគេមិនត្រឹមតែបង្ហាញជំនឿរបស់ខ្លួនថា "សំណុំរឿងនេះត្រូវបានបិទបញ្ចប់នៅចំពោះមុខ [អ.ប.ជ]" ប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងទៅហួសឆ្ងាយពីនេះដោយបានប្រកាសយ៉ាងច្បាស់លាស់ថា "នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង០០៤/២ ពាក់ព័ន្ធនឹង អោ អាន *នៅពេលនេះ ឬ នៅពេលអនាគតឡើយ*"[64]។

44. អ.ជ.ត.ក បានសម្រេចថា ការនៅស្ងៀមអាចស្មើទៅនឹងសេចក្តីសម្រេចមួយ ដែលរំលត់កិច្ចដំណើរការនីតិវិធីជាធរមាន[65]។ ហើយសេចក្តីសម្រេចរបស់ អ.ជ.ស.ដ មិនបំពេញកិច្ចក្នុង

---

ដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ("សេចក្តីសម្រេច អ.ជ.ត.ក លើវិធាន៣៥") កថាខណ្ឌ២៥។

[61] សំណុំរឿង០០២-ឯកសារ **E163/5/1/13** សេចក្តីសម្រេច អ.ជ.ត.ក លើវិសាលភាពក្នុងសំណុំរឿង ០០២/១ កថាខណ្ឌ៣០។

[62] ដូចដែលបានពិភាក្សាក្នុងផ្នែកប្រវត្តិនីតិវិធី *យោងខាងលើ*។

[63] *សូមមើល* កថាខណ្ឌ៣០ *យោងខាងលើ*។

[64] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២ កថាខណ្ឌចុងក្រោយបំផុត សង្កត់ន័យបន្ថែម។

[65] *សូមមើលឧទាហរណ៍* សំណុំរឿង០០២-ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ("សេចក្តីសម្រេចលើកទីពីររបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី") កថាខណ្ឌ ២១-២៦ (អ.ជ.ត.ក កត់សម្គាល់ថា អ.ជ.ស.ដ បានខកខានមិនបានផ្តល់នូវផែនការច្បាស់លាស់ ឬព័ត៌មានណាមួយទាក់ទងនឹងដំណើរការនៃសំណុំរឿង០០២ និងមិនបានដោះស្រាយបញ្ហាណាមួយចំពោះថាតើមានការជំនុំជម្រះជាបន្តបន្ទាប់ណាខ្លះអាចនឹងត្រូវធ្វើឡើង។ អ.ជ.ត.ក បានសម្រេចថា ការណ៍នេះនាំឱ្យមានការផ្អាក *តាមព្រឹត្តិន័យ* នៃកិច្ចដំណើរ

សំណុំរឿង០០៤/២ បំពេញតាមលក្ខខណ្ឌនេះ។ ជារួម អ.ជ.ស.ដ បានរំលត់ជាធរមាននូវកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អោ អាន ដោយមិនបានឈានទៅដល់សាលក្រម និងមិនបានទុកឱ្យភាគីនូវឱកាសប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមទេ[66]។ សម្រាប់មូលហេតុដូចបានរៀបរាប់ទាំងនេះ "សេចក្តីសម្រេច" របស់ អ.ជ.ស.ដ ស្ថិតក្រោមការប្តឹងសាទុក្ខជាបន្ទាន់ អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង។

45. វិធាន១០៧ នៃវិធានផ្ទៃក្នុង ចែងថា សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ដែលបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ ដូចដែលមានចែងក្នុងវិធាន ១០៤(៤)(ក) ត្រូវតែដាក់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃកាលបរិច្ឆេទរបស់សេចក្តីសម្រេច ឬការជូនដំណឹងរបស់វា។ សេចក្តីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា ត្រូវបានជូនដំណឹងតាមរយៈសារអេឡិកត្រូនិចទៅកាន់ភាគីនៃសំណុំរឿង ០០៤/២ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ដែលធ្វើឱ្យបណ្តឹងសាទុក្ខនេះដល់កាលកំណត់ដាក់នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ ២០២០[67]។

---

ការនីតិវិធី ដែលមិនមានការសន្យាច្បាស់លាស់អំពីការបន្ត ដើម្បីអនុញ្ញាតឱ្យឈានដល់សាលក្រមលើអង្គសេចក្តី សម្រាប់ផ្នែកនៃការចោទប្រកាន់ដែលនៅសល់ក្នុងដីកាដំណោះស្រាយ។ បណ្តឹងសាទុក្ខនេះត្រូវបានរកឃើញថាអាចទទួលយកបាន តាមមាត្រា ១០៤(៤)(ក))។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **A189/I/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ២២-២៤ (បានសន្និដ្ឋានថាការបរាជ័យរបស់ ស.ច.ស ក្នុងការសម្រេចលើសំណើរបស់មេធាវីការពារក្តីឱ្យឆាប់ដូចដែលអាចធ្វើបាន ក្នុងកាលៈទេសៈដែលការពន្យារពេលធ្វើសេចក្តីសម្រេច រារាំងមិនឱ្យជនត្រូវចោទមិនឱ្យមានលទ្ធភាពទទួលបានអត្ថប្រយោជន៍ដែលខ្លួនស្វែងរកដែលមានតម្លៃស្មើទៅនឹងការបដិសេធតាមការសន្មតនៃពាក្យសុំនោះ ដែលអាចប្តឹងឧទ្ធរណ៍បាន)។ ឯកសារ **A117/2/2** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើលើកទីបួនរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ៨។

[66] សំណុំរឿង០០២-ឯកសារ **E284/4/8** សេចក្តីសម្រេចលើកទីពីររបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ២១។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **E138/1/7** សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ១៥។ សំណុំរឿង០០២-ឯកសារ **E163/5/1/13** សេចក្តីសម្រេច អ.ជ.ត.ក លើវិសាលភាពក្នុងសំណុំរឿង ០០២/១ កថាខណ្ឌ២២។ សំណុំរឿង០០២-ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ កថាខណ្ឌ១៧។

[67] *សូមមើល* សារអេឡិចត្រូនិចពី លឹម ស៊ុយហុង ក្រឡាបញ្ជីរបស់ អ.ជ.ស.ដ ក្រោមចំណងជើងថា "សេចក្តីថ្លែងការណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ម៉ោង៖ ១:៤៩ រសៀល *(ភ្ជាប់ជាឧបសម្ព័ន្ធ ជ)*។ វិធាន៣៩(៣)។ ស.ព.អ កត់សម្គាល់ថា វិធាន ១០៦ ណែនាំថា បណ្តឹងសាទុក្ខភ្លាមៗត្រូវដាក់ទៅកាន់ អ.ជ.ស.ដ។ ដោយសារ

## ២. បណ្តឹងសាទុក្ខអាចទទួលយកបានអនុលោមតាមយុត្តាធិការផ្ទាល់របស់ អ.ជ.ត.ក

46. *សម្រាប់គោលបំណងវែកញែក* សូម្បីតែសន្មត់ថា ភាពនៅស្ងៀមរបស់ អ.ជ.ស.ដ និង សេចក្តីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា មិនបង្កើតបានជា "សេចក្តីសម្រេច" មួយ ដែលអាចប្តឹងសាទុក្ខបានអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ ស.ព.អ សន្និដ្ឋានថា អ.ជ.ត.ក ត្រូវតែស្តាប់សវនាការលើបណ្តឹងសាទុក្ខនេះ អនុលោមតាមយុត្តាធិការរបស់ខ្លួនផ្ទាល់។ អ.ជ.ត.ក បានសម្រេចពីមុនថា ខ្លួនមានយុត្តាធិការដើម្បីពិចារណាលើបណ្តឹងសាទុក្ខ "ពាក់ព័ន្ធទៅនឹងកាលៈទេសៈចាំបាច់ដែលតម្រូវឱ្យមានការធានានូវកិច្ចការរដ្ឋបាលតុលាការឱបានល្អ"[68]។ ខ្លួនក៏បានថ្លែងផងដែរថា ដើម្បីធានានូវការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌ និងដើម្បីបំពេញបេសកកម្មរបស់តុលាការឱ្យបានត្រឹមត្រូវ ស្ថាប័នតុលាការនៃ អ.វ.ត.ក ទាំងអស់ ត្រូវតែមានអំណាច *គ្រប់ពេលទាំងអស់* ដើម្បីធ្វើអ្វីដែលចាំបាច់ដើម្បីរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងការគោរពយុត្តិធម៌[69]។

47. តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតបានទទួលស្គាល់អំណាចរបស់អង្គជំនុំជម្រះ ក្នុងការអនុវត្តយុត្តាធិការផ្ទាល់របស់ខ្លួនដើម្បីដោះស្រាយបញ្ហា ក្នុងពេលអវត្តមានបទប្បញ្ញត្តិលក្ខន្តិកៈជាក់លាក់។ ការណ៍នេះរួមបញ្ចូលទាំងកាលៈទេសៈទាំងឡាយ ដែលក្នុងនោះមិនមានតុលាការណាមានអំណាចប្រកាសលើបញ្ហានោះ ដោយសារតែ "ការរាំងស្ទះផ្នែកច្បាប់ ឬឧបសគ្គផ្នែកអនុវត្ត" នៅពេលដែលវាចាំបាច់ត្រូវដោះស្រាយចន្លោះប្រហោងដែលអាចមាននៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ឬនៅពេលដែលតុលាការនោះត្រូវការដើម្បីធានាថា យុត្តិធម៌មិនត្រឹមតែធ្វើបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានគេ*មើលឃើញ* ថានឹងធ្វើបានផងដែរ[70]។ កាលៈទេសៈទាំងនេះអាចអនុវត្តបានចំពោះស្ថានភាព

---

តែលក្ខណៈពិសេស និងមិនធម្មតានៃបណ្តឹងសាទុក្ខនេះ និងប្រវត្តិនៃរឿងក្តីមកទល់កាលបរិច្ឆេទនេះ ស.ព.អ នឹងដាក់បណ្តឹងសាទុក្ខនេះទៅ អ.ជ.ស.ដ និងទៅកាន់ អ.ជ.ត.ក ដោយផ្ទាល់ផងដែរ។

[68] សំណុំរឿង០០២-ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ កថាខណ្ឌ ១៧។

[69] សំណុំរឿង០០២-ឯកសារ **E116/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើភាពត្រឹមត្រូវ") កថាខណ្ឌ ៣០ (អ.ជ.ត.ក ក៏បានថ្លែងផងដែរថាវាត្រូវបាន "បង្កើតឡើង យ៉ាងជាក់លាក់នៅកម្រិតអន្តរជាតិ" ដែលអំណាចនេះដោះស្រាយការពាក់ព័ន្ធជាមួយនឹង "ការជ្រៀតជ្រែកចូលក្នុងកិច្ចការ រដ្ឋបាលរបស់តុលាការ" ដែលត្រូវបានប្រគល់ទៅឱ្យតុលាការ "ដោយសារតែជាតួនាទីផ្នែកតុលាការ")។

[70] *សូមមើល ឧទា. នៅក្នុង the Matter of El Sayed*, សំណុំរឿង CH/AC/2010/02 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់របស់ចៅក្រមនៃអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងយុត្តាធិការ និងតួនាទី អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែ

វិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៤៥ ("[យុត្តាធិការដែលមានជាប់ជាមួយ] អាចត្រូវបានអនុវត្ត ជាពិសេស នៅពេលដែលមិនមានតុលាការណាផ្សេងទៀតមានអំណាចត្រូវប្រកាសពីបញ្ហាផ្លូវច្បាប់បន្ទាប់បន្សំ នៅលើករណីនៃការជំទាស់ខាងផ្លូវច្បាប់ ឬឧបសគ្គក្នុងការប្រតិបត្តិ។ ដូច្នេះ យុត្តាធិការដែលមានជាប់ជាមួយ គឺជាជំនួយ ឬជាបន្ទាប់បន្សំ ទៅនឹងយុត្តាធិការចម្បង និងត្រូវបានប្រគល់ឱ្យជាការចាំបាច់ ដោយតម្រូវការដាច់ខាត ដើម្បីធានាបាននូវការគ្រប់គ្រងវិស័យយុត្តិធម៌ដ៏ល្អ និងត្រឹមត្រូវ រួមទាំងការគោរពយ៉ាងពេញលេញនូវសិទ្ធិមនុស្សជាធរមាន របស់ជនទាំងអស់ដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីអន្តរជាតិដែលនៅលើវានេះ អង្គជំនុំជម្រះបានបញ្ជាក់[យ៉ាងច្បាស់លាស់]ពីយុត្តាធិការ") កថាខណ្ឌ ៤៦, ៤៨ ("ការអនុវត្តរបស់ស្ថាប័នយុត្តិធម៌អន្តរជាតិបង្ហាញថា វិធានដែលផ្តល់ឱ្យអង្គជំនុំជម្រះអន្តរជាតិដោយមានយុត្តាធិការដែលមានជាប់ជាមួយនេះ មានគោលបំណងជាទូទៅ ក្នុងការដោះស្រាយនូវការខ្វះចន្លោះ ដែលអាចមាន នៅក្នុងបទប្បញ្ញត្តិច្បាប់នៃកិច្ចដំណើរការណីតិវិធី")។ *រដ្ឋអាជ្ញា ទល់នឹង Blagojević & Jokić* សំណុំរឿង IT-02-60-T សេចក្តីសម្រេចលើញត្តិរបស់ក្រុមប្រឹក្សាមេធាវីឯករាជរបស់ Vidoje Blagojevic ក្នុងការបង្គាប់ឱ្យក្រឡាបញ្ជីចាត់តាំងតំណាង និងសហក្រុមប្រឹក្សាមេធាវីថ្មី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ១១២, ១១៤ (អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខណៈដែលវាមិនត្រូវបានតម្រូវឱ្យបំពេញកិច្ចអ្វីបន្ថែមទេនោះ វានៅមានផលប្រយោជន៍ និងការប្តេជ្ញាចិត្តក្នុងការធានាថា "យុត្តិធម៌មិនមែនគ្រាន់តែត្រូវបានសម្រេចប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែយុត្តិធម៌ត្រូវបានឃើញថាត្រូវបានសម្រេច"។ ដូច្នេះ វាបានបង្គាប់ឱ្យមានដំណាក់កាលពិសេសដើម្បីបំពេញកិច្ច ដែលនឹងតំណាងឱ្យយ៉ាងពេញលេញនូវផលប្រយោជន៍របស់ជនជាប់ចោទ)។ *រដ្ឋអាជ្ញា ទល់នឹង Beqaj* សំណុំរឿង IT-03-66-T-R77 សេចក្តីសម្រេចលើការប៉ុនប៉ងចោទប្រកាន់ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៩ ("អង្គជំនុំជម្រះរបស់តុលាការបានបញ្ជាក់ជាដដែលៗថា អំណាចដែលមានជាប់ជាមួយរបស់អង្គជំនុំជម្រះនេះ ដែលមានអត្ថិភាពឯករាជពីការយោងតាមផ្លូវច្បាប់ណាមួយ ដើម្បីដាក់ទណ្ឌកម្មទៅលើការប្រព្រឹត្តដែលទោរទន់ទៅរកការបង្កជាឧបសគ្គ ភាពលំអៀង ឬ ការរំលោភលើការគ្រប់គ្រងវិស័យយុត្តិធម៌របស់តុលាការ។ អំណាចនេះ គឺចាំបាច់ដើម្បីធានាថា ការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះគឺមិនបង្អាក់ទឹកចិត្ត ហើយមុខងាររបស់តុលាការជាមូលដ្ឋានត្រូវបានការពារ"), កថាខណ្ឌ ១០-១២ (និង ច្បាប់យុត្តិសាស្ត្រដែលបានរៀបរាប់នៅក្នុងនោះ), កថាខណ្ឌ ១៣ ("ចៅក្រមនៃអង្គជំនុំជម្រះនេះ អនុវត្តនូវអំណាចដែលមានជាប់ជាមួយ ដើម្បីចាត់វិធានការចាំបាច់ក្នុងការធានាពីសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ដែលជាទីបំផុតទៅនឹងរក្សាបាននូវការគោរពយុត្តិធម៌")។ *រដ្ឋអាជ្ញា ទល់នឹង Blaškić* សំណុំរឿង IT-95-14 សាលដីកាលើសំណើរបស់សាធារណរដ្ឋក្រូអាស៊ី សុំឱ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី II នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៧ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ កថាខណ្ឌ ៣៣, ៣៥ (អំណាចដែលមានជាប់ជាមួយរបស់អង្គជំនុំជម្រះ ក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់តុលាការចាំបាច់សម្រាប់ការអនុវត្តនូវយុត្តាធិការដំបូង គឺជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធិទៅនឹងលទ្ធភាពរបស់អង្គជំនុំជម្រះ ក្នុងការចេញបេសកកម្មដែលមានការជឿជាក់ទៅលើវា)។ *Barayagwiza ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿង ICTR-97-19-AR72 សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៦ ("ជាទូទៅ វាត្រូវបានទទួលស្គាល់ថា តុលាការមានអំណាចដែលត្រួតត្រាមើល ដែលអាចនឹងត្រូវបានប្រើប្រាស់នៅក្នុងផលប្រយោជន៍នៃយុត្តិធម៌ [...]។ ការប្រើប្រាស់នូវអំណាចដែលត្រួតត្រាមើលបែបដូច្នេះ បម្រើឱ្យមុខងារបីយ៉ាង៖ ផ្តល់នូវដំណោះស្រាយមួយចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ, ធ្វើឱ្យញញើតនឹងការប្រព្រឹត្តមិនល្អទៅថ្ងៃខាងមុខ ហើយនិង ធ្វើឱ្យប្រសើរឡើងនូវសុចរិតភាពនៃដំណើរការយុត្តិធម៌")។ *រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន* សំណុំរឿង ICTR-98-44-PT សេចក្តីសម្រេចស្តីពីការញែក Andre Rwamakuba ចេញពីការកែប្រែដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២២។

បច្ចុប្បន្នក្នុងសំណុំរឿង ០០៤/២ នេះ និងបង្ហាញបន្ថែមទៀតពីមូលហេតុដែល អ.ជ.ត.ក គួរតែធ្វើអន្តរាគមន៍។

48. ដោយសារតែភាពនៅស្ងៀម និងសេចក្តីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា របស់ អ.ជ.ស.ជ ការអនុវត្តឆន្ទានុសិទ្ធិរបស់ អ.ជ.ត.ក ក្នុងរឿងក្តីនេះគឺសំខាន់ខានមិនបាន ពីព្រោះថា អ.ជ.ត.ក ពេលនេះ គឺជាស្ថាប័នតែមួយគត់ដែលអាចរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងការពារផលប្រយោជន៍យុត្តិធម៌។ បញ្ហាសំខាន់ៗដែលជាចំណោទនោះគឺៈ ការសម្រេចសេចក្តីរបស់តុលាការនៃរឿងក្តីនៅចំពោះមុខតុលាការនេះស្របតាមច្បាប់ និងអង្គហេតុនៃរឿងក្តីនីមួយៗ ការសម្រេចសេចក្តីក្នុងរឿងក្តីដោយចៅក្រមដែលត្រឹមត្រូវយុត្តិធម៌ មិនលម្អៀង និងឯករាជ្យ និងការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដូចមានចែងនៅក្នុងវិធាន ២១(១) រួមបញ្ចូលទាំងភាពត្រឹមត្រូវផ្នែកនីតិវិធី តម្លាភាព សិទ្ធិធ្វើសវនាការ និងសិទ្ធិទទួលបានមតិយោបល់ដែលមានសំអាងហេតុ នៅចំពោះមុខចៅក្រមមិនលម្អៀង និងឯករាជ្យ[71]។ ជាងនេះទៀត ប្រសិនបើ អ.ជ.ត.ក បដិសេធមិនព្រមធ្វើអន្តរាគមន៍ទេនោះ សិទ្ធិប្តឹងសាទុក្ខនឹងប្រែទៅជាគ្មានន័យ ដោយសារតែភាគីនានានឹងត្រូវបានបន្សល់ទុកឲ្យនូវរឿងក្តីមួយដែលត្រូវបានបង្កកចោល និងមិនមានដំណោះស្រាយណាបន្តទៀត។ ជាចុងក្រោយ អន្តរាគមន៍របស់ អ.ជ.ត.ក គឺចាំបាច់ដើម្បីធានាសច្ចភាពផ្លូវច្បាប់ ព្រោះថាការសម្រេចសេចក្តីនៃសំណុំរឿង ០០៣ និង០០៤ ដែលបច្ចុប្បន្ននេះកំពុងនៅចំពោះមុខ អ.ប.ជ ក្នុងដំណាក់កាលប្តឹងឧទ្ធរណ៍រៀងៗខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា នឹងទំនងជាមានលទ្ធផលជាប់គាំងដូចដែលបានកើតឡើងក្នុងសំណុំរឿង ០០៤/២ នេះដែរ។

---

[71] *កត់សម្គាល់ថា* ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីបញ្ហានៃការរំលោភយ៉ាងធ្ងន់ធ្ងរ និងច្រំដែលៗ ទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ រួមទាំង សិទ្ធិក្នុងការបានស្តាប់ សិទ្ធិក្នុងការមានតំណាង សិទ្ធិក្នុងការមានភាពជាក់លាក់ខាងផ្លូវច្បាប់ និង សិទ្ធិក្នុងការមានតម្លាភាព និងមានសាធារណភាពនៃកិច្ចដំណើរការនីតិវិធី។ *កត់សម្គាល់បន្ថែមថា* បើទុកណាជាបញ្ហាទាំងនេះត្រូវបានលើកឡើងនៅក្នុងឯកសារ **D359/33 & D360/42** សំណើសុំការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២, ៤, ២៧-៤៥ ក៏ដោយក៏សារណានេះត្រូវបានដាក់បន្ទាប់ពីលោកប្រធាន អ.ប.ជ បានប្រកាសថា អ.ប.ជ នឹងមិនចាត់ការបន្ថែមទៀតទេ ហើយរហូតមកទល់ពេលនេះ អ.ប.ជ មិនមានវិនិច្ឆ័យសេចក្តីលើបញ្ហាទាំងនេះនោះទេ។ សារណាពន្យល់ថា អ.ប.ជ គឺជាអង្គជំនុំជម្រះតែមួយគត់ដែលមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សំណើដើម្បីសុំការពារសិទ្ធិរបស់ខ្លួន ដោយហេតុថា មិនមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរូបណាមួយត្រូវបានទទួលស្គាល់ដោយ OA ឬ អ.ប.ជ នោះទេ ហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានតួនាទីជាស្វ័យប្រវត្តិដើម្បីធ្វើសារណាដាក់ជូនទៅ អ.ជ.ស.ជ ឬ អ.ជ.ត.ក នោះទេ (មានតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នេះនៅដំណាក់កាលជំនុំជម្រះលើអង្គសេចក្តី និងដំណាក់កាលបន្តបន្ទាប់ទៀត)។

49. ជារួម ស.ព.អ សន្និដ្ឋានថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាននៅចំពោះមុខ អ.ជ.ត.ក។ ភាពនៅស្ងៀមរបស់ អ.ជ.ស.ដ មានតម្លៃស្មើនឹងការរំលត់ជាធរមានស្របតាមយុត្តិសាស្ត្រ និងថា អាចប្តឹងសាទុក្ខបានទៅ អ.ជ.ត.ក នៅក្រោមវិធាន ១០៤(៤)(ក)។ អ.ជ.ត.ក ក៏មានសិទ្ធិអំណាចអនុវត្តយុត្តាធិការផ្ទាល់របស់ខ្លួន "ដើម្បីសម្រេចបញ្ចប់លើបញ្ហាអង្គច្បាប់ដែលស្ថិតនៅចំពោះមុខខ្លួនឱ្យបានដាច់ស្រេច" និងដោះស្រាយចំពោះ "អង្គសេចក្តី និង/ឬ បញ្ហា*នីតិវិធី*"[72]។

## ខ. អង្គសេចក្តី

### ១. អ.ជ.ស.ដ មានកំហុសអង្គច្បាប់ក្នុងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ តាមរយៈបរាជ័យរបស់ខ្លួនក្នុងដំណើរការធ្វើឱ្យរឿងក្តីទៅជំនុំជម្រះតាំងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ បានបន្ថែមជាចុងក្រោយទៅក្នុងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា របស់ខ្លួន

50. នៅក្នុងសេចក្តីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា នេះ អ.ជ.ស.ដ បានសម្រេចថា "ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានយល់ឃើញថា អង្គជំនុំជម្រះមួយនៃ អ.វ.ត.ក មិនអាចធ្វើចំណាត់ការតាមផ្លូវតុលាការបានឡើយ នៅពេលដែលអង្គជំនុំជម្រះនោះខ្វែងគំនិតគ្នាក្នុងការសម្រេចទៅលើចំណាត់ការតាមផ្លូវតុលាការនោះ"[73]។ គោលជំហរនេះមិនត្រឹមត្រូវតាមច្បាប់ឡើយ។ ប្រសិនបើ អ.ជ.ស.ដ អនុវត្តបទដ្ឋានច្បាប់ត្រឹមត្រូវនោះ អង្គជំនុំជម្រះនេះនឹងរកឃើញថា បរាជ័យរបស់ អ.ប.ជ ក្នុងការទទួលបានសំឡេងភាគច្រើនដែលតម្រូវដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ នាំឱ្យចាប់ផ្តើមគោលជំហរស្វ័យប្រវត្តិ "ជាមូលដ្ឋាន និងជាកត្តាកំណត់" ដែលជាមូលដ្ឋាននៃក្របខណ្ឌច្បាប់

---

[72] សំណុំរឿង០០២-ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើវិធាន៣៥ របស់ អ.ជ.ត.ក កថាខណ្ឌ ២៥ (សង្កត់ន័យបន្ថែម)។ *សូមមើលផងដែរ* ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១២២ (ជាឯកច្ឆ័ន្ទ)៖ "ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស ដោយផ្អែកទៅលើច្បាប់ សេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ (*jurisdictio*) គឺជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពង់ខ្ពស់បំផុតរបស់ចៅក្រម។ ហេតុដូច្នេះ ការប្រកាសសម្រេចវិនិច្ឆ័យ និងការដោះស្រាយបញ្ហាដែលជាជម្លោះ ត្រូវមានឥទ្ធិពល និងជាកាតព្វកិច្ចផ្លូវច្បាប់ (*imperium*) ដែលខុសពីសារណារបស់ភាគី។ ប៉ុន្តែ *ចៅក្រមមិនអាចគេចចេញពីការវិនិច្ឆ័យលើបញ្ហាដែលនៅចំពោះមុខខ្លួន* ឬគេចចេញពីការឈានទៅសន្និដ្ឋាន ដែលសម្រេចដោយប្រសិទ្ធិភាពទៅលើបញ្ហានេះទេ" (សង្កត់ន័យបន្ថែម)។ សេចក្តីថ្លែងការណ៍នៅទីក្រុងប៉េកាំង ស្តីពីគោលការណ៍ឯករាជភាពនៃប្រព័ន្ធតុលាការនៅក្នុងតំបន់ LAWASIA, សមាគមអ្នកច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧ ("គោលការណ៍ទីក្រុងប៉េកាំង") មាត្រា ៣៖ "ឯករាជភាពនៃតុលាការតម្រូវឱ្យ៖ ក) តុលាការត្រូវសម្រេចពីបញ្ហានានាដែលនៅចំពោះមុខខ្លួន ដោយត្រូវទៅតាមការវាយតម្លៃមិនលំអៀងនៃអង្គហេតុ និងការយល់ឃើញរបស់ខ្លួនស្តីពីច្បាប់ ដោយពុំមានឥទ្ធិពលមិនត្រឹមត្រូវ, ដោយចំពោះ ឬដោយប្រយោល, ពីប្រភពណាក៏ដោយ; និង ខ) តុលាការមានយុត្តាធិការ, ដោយចំពោះ ឬតាមការពិនិត្យឡើងវិញ, ទៅលើ *រាល់បញ្ហាទាំងអស់នៃលក្ខណៈដែលត្រូវទូទាត់ជាមួយគ្នា*" (សង្កត់ន័យបន្ថែម)។

[73] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២។

អ.វ.ត.ក ទាំងមូល[74]។ ដូចដែលបានកំណត់ដោយគោលជំហរនោះ ជាវិបាក អ.ជ.ស.ដ គួរបាន រកឃើញថា ខ្លួនត្រូវបានទទួលយកសំណុំរឿង ០០៤/២ នេះ នៅត្រឹមថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ នៅពេលដែលសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដែលតម្រូវ មិនអាចរកបាន ហើយខ្លួនគួរ បានបង្គាប់ទៅផ្នែកគ្រប់គ្រងតុលាការឱ្យបញ្ជូនសំណុំរឿងនេះ ដែលជាវិធានការមួយដែលកើតចេញ ពីយុត្តាធិការរបស់ខ្លួនមានលើរឿងក្ដីនេះ ឬក្នុងការអនុវត្តយុត្តាធិការផ្ទាល់របស់ខ្លួន។

51. កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ទាំងពីរនេះចែងថា នៅពេលដែលសហព្រះរាជអាជ្ញា ឬ ស.ច.ស ខ្វែងយោបល់គ្នាលើការដំណើរការរឿងក្ដីទៅមុខ រឿងក្ដីនោះបន្តទៅដំណាក់កាលបន្ទាប់ ប្រសិនបើមិនមានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដើម្បីរារាំងដំណើរការទៅមុខរបស់វា ទេនោះ[75]។ ទោះបីជា ចៅក្រម អ.ប.ជ ខ្វែងយោបល់គ្នាលើផ្នែកសម្រេចសេចក្ដីនៃដីកាដំណោះ ស្រាយផ្ទុយគ្នាក៏ដោយ ក៏ពួកគេបានឯកភាពជាឯកច្ឆ័នលើគោលការណ៍ដែលថា ក្នុងករណីដែលមិន មានសេចក្ដីសម្រេចដោយសំឡេងភាគច្រើនលើសលុប គោលជំហរស្វ័យប្រវត្តិដែលថា "ការស៊ើប អង្កេតត្រូវតែបន្ត"[76] គឺជា "មុខងារសំខាន់នៃក្របខណ្ឌគតិយុត្តិ អ.វ.ត.ក"[77] និងជា "មូលដ្ឋាន និងជា កត្តាកំណត់"[78]។ ជាសំខាន់ ពួកគេបានសង្កត់ធ្ងន់ថា គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាននេះ "មិន អាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការ បកស្រាយជាបណ្ដាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យគោលការណ៍ស្នូលនេះ ក្លាយទៅជាគ្មានន័យ នោះទេ"[79]។

52. គោលជំហរស្វ័ប្រវត្តិក៏មានចែងនៅក្នុងវិធាន ៧៧(១៣)(ខ) ផងដែរ ដែលជា *វិធានពិសេស (lex specialis)* ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុដូច្នេះវាមានអាទិភាពលើពាក្យពេចន៍ទូទៅ

---

[74] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១២២ (ជាឯកច្ឆ័ន្ទ)។

[75] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤), ៦(៤), ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២០ថ្មី, ២៣ថ្មី។

[76] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១០៦ *ដោយការលើកឡើងពី* សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៧៥។

[77] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១០៦។

[78] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១១២។

[79] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១១២។ *សូមមើលផងដែរ* កថាខណ្ឌ ១១១ ដែល អ.ប.ប បានបញ្ជាក់ជាឯកច្ឆន្ទថា គោលបំណងនៃគោលជំហរស្វ័យប្រវត្តិ គឺដើម្បីធានាឱ្យមានយុត្តិធម៌ប្រកបដោយប្រសិទ្ធិភាព នៅក្នុងបរិបទ អ.វ.ត.ក និងដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធីដែលរារាំងដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី។

នៃវិធាន ៧៧(១៣)(ក) ទាក់ទងនឹងដីកាសម្រេចផ្សេងៗ “ក្រៅពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ”[80]។ ដូចគ្នានឹង “ដីកាបញ្ជូនរឿងទៅជំនុំជម្រះ” ដែរ “ដីកាសម្រេចលើកលែងចោទប្រកាន់” និង “ដីកាដំណោះស្រាយ” គឺជាពាក្យពេចន៍ដែលត្រូវបានកំណត់និយមន័យនៅក្នុងវិធានផ្ទៃក្នុង[81]។ ប្រសិនបើអ្នកធ្វើសេចក្តីព្រៀងមានបំណងដោះស្រាយជាក់លាក់លើផលប៉ះពាល់នៃបរាជ័យរបស់ អ.ប.ជ ក្នុងការបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់នោះ ពួកគេច្បាស់ជាបានធ្វើដូច្នោះនៅក្នុងវិធាន ៧៧(១៣)(ក) ហើយ ប៉ុន្តែបានជ្រើសរើសមិនធ្វើដូច្នោះទេ។ ផ្ទុយទៅវិញ វិធាន ៧៧(១៣)(ខ) អនុវត្តគោលបំណងច្បាស់លាស់របស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា នៅពេលពួកគេបញ្ចប់កិច្ចព្រមព្រៀង អ.វ.ត.ក[82] ហេតុដូច្នេះ វាត្រូវតែមានអានុភាពលុបលើ។

---

[80] ពាក្យឡាតាំងថា *lex specialis* (វិធានពិសេស) យោងទៅដល់ទ្រឹស្តីមួយទាក់ទងនឹងការបកស្រាយច្បាប់ ដែលទៅតាមវានេះ ច្បាប់ ដែលគ្រប់គ្រងទៅលើប្រធានបទជាក់លាក់ (*lex specialis*(វិធានទូទៅ)) លុបលើច្បាប់ដែលគ្រាន់តែគ្រប់គ្រងលើបញ្ហាទូទៅតែប៉ុណ្ណោះ (*lex generalis*)។

[81] *សូមមើល* វិធានផ្ទៃក្នុង ទំព័រទី ៨៣-៨៤។

[82] *សូមមើល ឧទា.* ឯកសារ **D324.30** លិខិតពីលោកអគ្គលេខាធិការ អ.ស.ប ជូនទៅ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០០០ កំណត់សម្គាល់ដែលបានភ្ជាប់ជាឧបសម្ព័ន្ធពីលោក Hans Corell ជូនទៅលោកអគ្គលេខាធិការ ប្រធានបទ៖ ការអំពាវនាវជាបន្ទាន់ពីប្រទេសកម្ពុជា - ជម្រើសនានាដើម្បីដោះស្រាយភាពខុសគ្នារវាង ចៅក្រមស៊ើបសួរ/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ EN 01326090 (នៅថ្ងៃជាមួយគ្នាដែល អ.ស.ប បានផ្តល់ជាដំបូងនូវមាត្រា ៧(៤) ដែលមានពាក្យពេចន៍ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា លោក Hans Corell ដែលជា អគ្គលេខាធិការរង ខាងកិច្ចការច្បាប់ និងក្រុមប្រឹក្សាអ្នកច្បាប់របស់ អ.ស.ប បានកត់ត្រានូវការសន្ទនាគ្នាជាមួយនឹងលោក សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានចរចារបស់រាជរដ្ឋាភិបាលកម្ពុជា ដោយការច្រានចោលនូវនូវការអំពាវនាវរបស់គាត់ក្នុងការមានលក្ខខណ្ឌតម្រូវមតិភាគច្រើនដាច់ខាតដើម្បី *អនុញ្ញាត* ឱ្យមានការបន្តកិច្ចស៊ើបសួរ ឬ ការចោទប្រកាន់។ លោក Hans Corell បានពន្យល់ថា យន្តការនៃការខ្វែងយោបល់គ្នាដូចដែលបានព្រាងនេះ មានន័យថា “លោក/អ្នក ចាំបាច់ត្រូវការមតិភាគច្រើនដាច់ខាតដើម្បីបញ្ឈប់កិច្ចស៊ើបសួរ ឬ ការចោទប្រកាន់”)។ ឯកសារ **D324.36** សេចក្តីថ្លែងការណ៍ដោយលោក អគ្គលេខាធិការរង Hans Corell នៅពេលចាកចេញពីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៣ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៣ EN 01326112។ *សូមមើលផងដែរ* ឯកសារ **D359/3/1.1.43** លោក David Scheffer “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទី៣ វ៉ូលូម III ឆ្នាំ២០០៨ ទំព័រទី ២៤៦ (EN 01598756) (លោក David Scheffer ឯកអគ្គរដ្ឋទូតគោចរ ស.រ.អា សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម មានការជាប់ទាក់ទងយ៉ាងសំខាន់នៅក្នុងកិច្ចចរចា អ.វ.ត.ក និងបានបញ្ជាក់នូវទស្សនៈដូចគ្នាថា៖ “មានវិធីតែមួយប៉ុណ្ណោះដែល ការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ *ត្រូវបានបញ្ឈប់* គឺថា ប្រសិនបើ [អ.ប.ជ] សម្រេចដោយសម្លេងភាគច្រើនដាច់ខាតថាវាត្រូវតែបញ្ឈប់។ សនិទានភាពនៅពីក្រោយនីតិវិធីនេះ គឺថា វារារាំង [ស.ច.ស] មួយ ឬ សហព្រះរាជអាជ្ញាមួយ មិនឱ្យរាំងខ្ទប់កិច្ចស៊ើបសួរ ឬ ការចោទប្រកាន់ រៀងៗខ្លួន ដោយការខកខានមិនបានឈានដល់ការព្រមព្រៀងគ្នាជាមួយនឹងដៃគូរបស់ខ្លួន ឬ ក៏គ្រាន់តែឃ្លាតចាកពីកិច្ចស៊ើបសួរ ឬ ការចោទប្រកាន់ បណ្តាលមកពីនយោបាយ ឬ ឥទ្ធិពលប្រភេទផ្សេងៗទៀត” (សង្កត់ន័យបន្ថែម))។

53. វិធាន ៧៧(១៣)(ខ) *តម្រូវ* ថា អ.ជ.ស.ជ ត្រូវទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដែលសំឡេងភាគច្រើនលើសលុបដែលតម្រូវមិនអាចទទួលបាន។ ជារួម ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតែ "មានសុពលភាព" ហើយ អ.ជ.ស.ជ *ត្រូវតែទទួលបណ្តឹង* ផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ យុត្តិសាស្ត្ររបស់ អ.ជ.ត.ក គាំទ្រលទ្ធផលនេះ ដោយបានសម្រេចថា៖

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ដោយមូលហេតុថា ជនត្រូវចោទម្នាក់ គឺជា ឬមិនមែនជាជនដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលុប ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[83]។

54. ដើម្បីឲ្យច្បាស់ អ.ជ.ត.ក បានពិភាក្សាពីសេណារីយ៉ូនេះក្នុងបរិបទដែល ស.ច.ស ណាម្នាក់ ឬទាំងពីរនាក់ ធ្វើការបញ្ជូន ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ផ្ទុយគ្នាដែលបានស្នើឡើងទៅ អ.ប.ជ តាមរយៈយន្តការដោះស្រាយការខ្វែងយោបល់ ដែលបានប្រមើលទុកជាមុនដោយវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណា លទ្ធផលជាសារធាតុរបស់ អ.ជ.ត.ក គឺអាចអនុវត្តបានស្មើគ្នាចំពោះស្ថានភាពបច្ចុប្បន្នដែល អ.ប.ជ មិនទទួលបានសំឡេងភាគច្រើនលើសលុបលើបញ្ហាថាតើ ចៅក្រមណាម្នាក់បានចេញខុសនូវដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួនដែរឬអត់នោះ។ ការសម្រេចផ្សេងពីនេះ ជាអ្វីដែលចៅក្រម អ.ប.ជ បានព្រមានជាឯកច្ឆ័ន្ទ - មានន័យថា គឺជាការទាត់ចោល ឬដកហូតនូវឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងនៃគោលជំហរស្វ័យប្រវត្តិ - ដែលនឹងនាំឲ្យមាន "លទ្ធផលផ្លូវច្បាប់ដែលមិនសមហេតុផលទាល់តែសោះ"[84]។ និយាយម្យ៉ាងទៀត វានឹងធ្វើឲ្យក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ទៅជាមោឃៈ។

55. វិធាន ៧៩(១) ក៏បានកំណត់ផងដែរថា អ.ជ.ស.ជ *ទទួលបណ្តឹង* ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ[85]។ អង្គហេតុដែលថា សំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ មិនបានប្តឹងឲ្យ អ.ជ.ស.ជ ទទួលយកសំណុំរឿងនេះ គឺមិនពាក់ព័ន្ធឡើយ ដោយហេតុថា ការប្រើពាក្យ "ឬ" នៃវិធាន ៧៩(១)

---

[83] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦៥ *ដោយការលើកឡើងពី* ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី, កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤), វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[84] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១១២។

[85] សង្កត់ន័យបន្ថែម។

ក៏អនុញ្ញាតឲ្យមានការប្តឹងឲ្យទទួលយក ដោយផ្អែកតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះពី ស.ច.ស ផងដែរ។ ពេលអានរួមគ្នាជាមួយវិធាន ១(២) នៃវិធានផ្ទៃក្នុង ការសំដៅណាមួយទៅលើ ស.ច.ស នៅក្នុងវិធានផ្ទៃក្នុង គឺរួមបញ្ចូលទាំង ស.ច.ស ដែលបំពេញកិច្ចតែម្នាក់ឯងផងដែរ។ ដូច្នេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនត្រូវបានបដិសេធដោយសំឡេងលើសលុបនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ នៅតែ "មានសុពលភាព" ហើយ អ.ជ.ស.ជ ត្រូវតែបានប្តឹងដោយដីកានេះ។

56. បទប្បញ្ញត្តិជាកាតព្វកិច្ចនៃវិធានទាំងនេះ ត្រូវបានគាំទ្របន្ថែមទៀតដោយគោលបំណងនៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក គឺដើម្បី "*កាត់សេចក្តី* មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម"[86]។ បទប្បញ្ញត្តិទាំងនេះ ក៏ស្របទៅនឹងគោលបំណងនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នាផងដែរ គឺដើម្បី "រារាំងការជាប់គាំងដែលធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ"[87]។

57. សម្រាប់មូលហេតុដូចបានរៀបរាប់ខាងលើ បរាជ័យខុសឆ្គងរបស់ អ.ជ.ស.ជ ក្នុងការអនុវត្តឲ្យបានត្រឹមត្រូវនូវគោលជំហរស្វ័យប្រវត្តិនេះ ធ្វើឲ្យសេចក្តីសម្រេចរបស់ខ្លួនគ្មានសុពលភាព។ ស.ព.អ សន្និដ្ឋានថា ពេលនេះមានតែអន្តរាគមន៍របស់ អ.ជ.ត.ក ទេ ទើបអាចធានាថា គោលជំហរស្វ័យប្រវត្តិដែលត្រូវបន្តទៅជំនុំជម្រះ ត្រូវបានអនុវត្តត្រឹមត្រូវ។ ការអនុវត្តផ្សេងពីនេះ គឺផ្ទុយទៅនឹងក្របខណ្ឌច្បាប់ អ.វ.ត.ក ទាំងមូល ជាការបដិសេធសិទ្ធិទទួលបានយុត្តិធម៌របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ និងធ្វើឲ្យខូចតម្លៃដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក។

## ២. អ.ជ.ស.ជ មានកំហុសអង្គច្បាប់ និងបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលខ្លួនបដិសេធមិនអនុវត្តយុត្តាធិការផ្ទាល់របស់ខ្លួន ដើម្បីបំពេញកាតព្វកិច្ចតុលាការជាចំបងរបស់ខ្លួន ក្នុងការសម្រេចលើបញ្ហាដែលត្រូវដោះស្រាយតាមច្បាប់នៅចំពោះមុខខ្លួន

58. អ.ជ.ស.ជ បដិសេធមិនអនុវត្តតាមច្បាប់ត្រឹមត្រូវ និងមានកំហុសជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនពេលសន្និដ្ឋានថាខ្លួនមិនមានសិទ្ធិអំណាចធ្វើការសម្រេច*ណាមួយ* លើសំណុំរឿង ០០៤/២។ ខណៈសេចក្តីសន្និដ្ឋាននេះត្រូវបានបង្ហាញថា ជាទស្សនៈរបស់ចៅក្រមជាតិ នៅក្នុងសេចក្តីថ្លែងការណ៍ថ្ងៃទី៣ ខែមេសា និងមិនមានទម្ងន់ជាសេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុប[88]

---

[86] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១ (សង្កត់ន័យបន្ថែម), ច្បាប់ អ.វ.ត.ក មាត្រា ១ (សង្កត់ន័យបន្ថែម)។

[87] *សូមមើល* ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ យោបល់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣២៣ និងការលើកឡើងនៅក្នុងនោះ។

[88] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២។

ទេនោះ ការបន្តភាពនៅស្ងៀមរបស់ អ.ជ.ស.ដ ទាក់ទងទៅនឹងសារណារបស់ភាគី និងការបង្វិលត្រឡប់មកវិញនៃសារណាទាំងនោះ បានបញ្ជាក់អំពីការបដិសេធរបស់អង្គជំនុំជម្រះទាំងមូលក្នុងការធ្វើសេចក្ដីសម្រេចណាមួយអំពីសំណុំរឿង ០០៤/២ នេះ[89]។

59. ការបដិសេធរបស់ អ.ជ.ស.ដ ក្នុងអនុវត្តយុត្តាធិការផ្ទាល់របស់ខ្លួនដើម្បីសម្រេចលើបញ្ហាដែលត្រូវដោះស្រាយតាមច្បាប់នៅចំពោះមុខខ្លួន ទាក់ទងនឹងការជាប់គាំងតាមផ្លូវតុលាការ បានមើលរំលងការប្រកាសរបស់ អ.ជ.ត.ក ថា ដើម្បីធានាឲ្យមានការជំនុំជម្រះមួយដែលត្រឹមត្រូវ និងដើម្បីបំពេញបេសកកម្មរបស់តុលាការនេះ ស្ថាប័ន អ.វ.ត.ក ទាំងអស់ ត្រូវតែមានអំណាច *គ្រប់ពេលវេលា* ដើម្បីធ្វើអ្វីដែលចាំបាច់ដើម្បីរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងការគោរពយុត្តិធម៌[90]។ វាក៏ជាការរំលោភលើកាតព្វកិច្ចក្រមសីលធម៌របស់ចៅក្រមផងដែរ[91] ដោយរួមបញ្ចូលទាំងភារកិច្ច "ក្នុង

[89] *សូមមើល* កថាខណ្ឌ ៧, ៩, ២២, ២៩-៣០, ៤២-៤៣, *យោងខាងលើ*។

[90] សំណុំរឿង០០២-ឯកសារ **E116/1/7** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើភាពត្រឹមត្រូវ កថាខណ្ឌ ៣០ (សង្កត់ន័យបន្ថែម)។ នៅក្នុងកថាខណ្ឌដដែល អ.ជ.ត.ក ក៏បានថ្លែងផងដែរថា វាគឺត្រូវបាន "បង្កើតឡើងយ៉ាងជាក់លាក់នៅកម្រិតអន្តរជាតិ" ដែលអំណាចនេះដោះស្រាយការពាក់ព័ន្ធជាមួយនឹង "ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ" ដែលត្រូវបានប្រគល់ទៅឲ្យតុលាការ "ដោយសារតែជាតួនាទីផ្នែកតុលាការ")"។

[91] *សូមមើល ឧទា.* ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី ("អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និង ដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ")។ ក្រមសីលធម៌ចៅក្រម បានអនុម័តដោយកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា២(១) ("ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និង ត្រូវធានាពីការបង្ហាញពីភាពមិនលម្អៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន"), មាត្រា៣(១) ("ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសីលធម៌ និង ដោយសេចក្ដីសុចរិតទៀងត្រង់តាមមុខនាទីរបស់ខ្លួន ដើម្បីលើកកំពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ"), មាត្រា៥(១) ("ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្ដីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបំពេញភារកិច្ចទាំងនោះ")។ គោលការណ៍ជាមូលដ្ឋានស្ដីពីឯករាជភាពរបស់តុលាការ យល់ព្រមដោយសេចក្ដីសម្រេចរបស់អគ្គលេខាធិការ លេខ ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥, គោលការណ៍ទី២ ("តុលាការត្រូវសម្រេចលើរឿងរ៉ាវនៅចំពោះមុខខ្លួនដោយមិនលំអៀង នៅលើមូលដ្ឋាននៃអង្គហេតុ និងដោយត្រូវទៅនឹងច្បាប់ ដោយពុំមានការដាក់កំរិត ឥទ្ធិពលមិនត្រឹមត្រូវ ការបញ្ចុះបញ្ចូល ការកៀបសង្កត់ ការបង្ខិតបង្ខំ ឬ ការជ្រៀតជ្រែក ដោយផ្ទាល់ ឬដោយប្រយោល ពីផ្នែកណាមួយ ឬដោយមូលហេតុអ្វីមួយ នោះឡើយ"), គោលការណ៍ទី៦ ("គោលការណ៍ស្ដីពីឯករាជភាពរបស់តុលាការ ត្រូវមានសិទ្ធិ និង តម្រូវឲ្យតុលាការធានាថា កិច្ចដំណើរការនីតិវិធីតុលាការត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ហើយថា សិទ្ធិរបស់ភាគីត្រូវបានគោរព")។ *សូមមើលផងដែរ* គោលការណ៍ទីក្រុងប៉េកាំង មាត្រា ៣ ("ឯករាជភាពនៃតុលាការតម្រូវឲ្យ៖ ក) តុលាការត្រូវសម្រេចពីបញ្ហានានាដែលនៅចំពោះមុខខ្លួន ដោយត្រូវទៅតាមការវាយតម្លៃមិនលំអៀងនៃអង្គហេតុ និងការយល់ឃើញរបស់ខ្លួនស្ដីពីច្បាប់ ដោយពុំមានឥទ្ធិពលមិនត្រឹមត្រូវ, ដោយចំពោះ ឬដោយប្រយោល, ពីប្រភពណាក៏ដោយ;

ការប្រកាសដោយផ្អែកទៅលើច្បាប់ នូវសេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ" ដែល "ជាចំណុចសំខាន់នៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពស់បំផុតរបស់ចៅក្រម"[92]។

60. ប្រសិនបើ អ.ជ.ស.ដ អនុវត្តតាមច្បាប់ត្រឹមត្រូវ និងបានយកយុត្តាធិការផ្ទាល់ខ្លួនមកប្រើនោះ ម្ល៉េះខ្លួនបានរកឃើញថា ប្រធាន អ.ប.ជ មិនមានសិទ្ធិអំណាចរារាំងការបញ្ជូនសំណុំរឿងនេះទៅកាន់ អ.ជ.ស.ដ ទេ[93] ហើយអង្គជំនុំជម្រះនេះនឹងបានបង្គាប់ឲ្យបញ្ជូនសំណុំរឿងនេះទៅ អ.ជ.ស.ដ ហើយ ជាជាងនៅស្ងៀមចាំតែ អ.ប.ជ ទើបអាចផ្តួចផ្តើមវិធានការបែបនោះបាន[94]។

---

និង ខ) តុលាការមានយុត្តាធិការ, ដោយចំពោះ ឬតាមការពិនិត្យឡើងវិញ, ទៅលើ *រាល់បញ្ហាទាំងអស់នៃលក្ខណៈដែលត្រូវទូទាត់ជាមួយគ្នា*" (សង្កត់ន័យបន្ថែម)")។ សំណុំរឿង០០២-ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើវិធាន៣៥ របស់ អ.ជ.ត.ក កថាខណ្ឌ ២៥។

[92] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១២២ (ជាឯកច្ឆ័ន្ទ)។

[93] វិធាន៧៧ នៃវិធានផ្ទៃក្នុង បានកម្រិតអំណាចដោយតំណែងរបស់ប្រធាន អ.ប.ជ ឲ្យ៖ ផ្ទៀងផ្ទាត់មើលថា សំណុំរឿងនេះមានភាពពេញលេញ និង កំណត់កាលបរិច្ឆេទសវនាការ (*សូមមើល* វិធាន៧៧(៣)(ក) នៃវិធានផ្ទៃក្នុង); កំណត់ថាតើសវនាការណាខ្លះអាចត្រូវប្រើប្រាស់ពេលវេលាយូរ ដូច្នេះហើយ តម្រូវឲ្យចៅក្រម អ.ប.ជ បម្រុង មានវត្តមាន (*សូមមើល* វិធាន៧៧(៧) នៃវិធានផ្ទៃក្នុង); សម្រេច បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយចៅក្រមដទៃទៀត ឲ្យលើកពេលសវនាការ ឬ តែងតាំងចៅក្រមបម្រុងឲ្យជំនួសកន្លែងរបស់ចៅក្រមដែលអវត្តមាន ដើម្បីឲ្យនីតិវិធីអាចបន្តទៅបាន (*សូមមើល* វិធាន៧៧(៨) នៃវិធានផ្ទៃក្នុង); ចាត់តាំងចៅក្រមជាតិមួយរូប និង ចៅក្រមអន្តរជាតិមួយរូបជាសហចៅក្រមរបាយការណ៍ (*សូមមើល* វិធាន៧៧(១០) នៃវិធានផ្ទៃក្នុង); និង សម្រេចបដិសេធ ឬ អនុញ្ញាតឲ្យមានការដោះលែងជនត្រូវចោទដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅពេលដែល ស.ច.ស បង្គាប់ឲ្យដោះលែង ឬ សម្រេចឲ្យលើកលែងការចោទប្រកាន់, (*សូមមើល* វិធាន ៧៧(១៥) នៃវិធានផ្ទៃក្នុង)។ *សូមមើលផងដែរ* ឯកសារ **D359/35 & D360/44** អនុស្សរណៈថ្ងៃទី២៩ ខែមករា របស់ចៅក្រមអន្តរជាតិ អ.ប.ជ ទំព័រទី៥។ អំពើកម្មជាឯកតោភាគីរបស់ប្រធាន អ.ប.ជ ក៏ត្រូវបានល្មើសបទប្បញ្ញត្តិគោលការណ៍ជាមូលដ្ឋាននៃវិធានស្តីពីសម្លេងភាគច្រើនដាច់ខាត និងគោលជំហរជាស្វ័យប្រវត្តិ ដែលទាំងពីរនេះ បង្កើតបានជាការការពារប្រឆាំងនឹងបុគ្គលដែលប៉ុនប៉ងរាំងខ្ទប់សំណុំរឿងមិនឲ្យដំណើរការទៅមុខ។ *សូមមើល ឧទា.* ឯកសារ **D359/3/1.1.43** លោក David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទី៣ វ៉ុលូម III ឆ្នាំ២០០៨ ទំព័រទី ២៤៦ (EN 01598756)។ លោក David Scheffer ឯកអគ្គរដ្ឋទូតគោចរ ស.រ.អា សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម មានការជាប់ទាក់ទងយ៉ាងសំខាន់នៅក្នុងកិច្ចចរចា អ.វ.ត.ក និងបានបញ្ជាក់នូវទស្សនៈដូចគ្នាថា៖ "មានវិធីតែមួយប៉ុណ្ណោះដែល ការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ *ត្រូវបានបញ្ឈប់* គឺថា ប្រសិនបើ [អ.ប.ជ] សម្រេចដោយសម្លេងភាគច្រើនដាច់ខាតថាវាត្រូវតែបញ្ឈប់។ សនិទានភាពនៅពីក្រោយនីតិវិធីនេះ គឺថា វារារាំង [ស.ច.ស] មួយ ឬ សហព្រះរាជអាជ្ញាមួយ មិនឲ្យរាំងខ្ទប់កិច្ចស៊ើបសួរ ឬ ការចោទប្រកាន់ រៀងៗខ្លួន ដោយការខកខានមិនបានឈានដល់ការព្រមព្រៀងគ្នាជាមួយនឹងដៃគូរបស់ខ្លួន ឬ ក៏គ្រាន់តែឃ្លាតចាកពីកិច្ចស៊ើបសួរ ឬ ការចោទប្រកាន់ បណ្តាលមកពីនយោបាយ ឬ ឥទ្ធិពលប្រភេទផ្សេងៗទៀត" (សង្កត់ន័យបន្ថែម))។

[94] *សូមមើល* សំណុំរឿង០០២-ឯកសារ **E9** ដីកាបង្គាប់ឲ្យត្រៀមរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ("ដីកាបង្គាប់ឲ្យត្រៀមរៀបចំរបស់ អ.ជ.ស.ដ") សេចក្តីផ្តើម ត្រង់ KH 00635748 (កត់សម្គាល់ថា អ.ជ.ស.ដ ត្រូវបានប្តឹងឲ្យទទួលយក អនុលោមតាមសេចក្តីសម្រេចនានាដែលបានប្រគល់ជូនទៅ អ.ប.ជ កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១) និង

61. ការអនុវត្តឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ នេះ មានសារសំខាន់ណាស់ក្នុងការរក្សាសុចរិតភាពរបស់តុលាការនេះ ការពារសិទ្ធិរបស់ភាគី និងទុកជាយុត្តិសាស្ត្រមានសំអាងហេតុសម្រាប់កាលៈទេសៈនីតិវិធីស្រដៀងគ្នានេះ ដែលទំនងជាអាចកើតមានក្នុងសំណុំរឿង ០០៣ និង ០០៤។ ប្រសិនបើ អ.ជ.ស.ដ បានអនុវត្តច្បាប់ត្រឹមត្រូវ និង/ឬ បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវនោះ សំណុំរឿង ០០៤/២ នេះ ម្ល៉េះបានបន្តទៅជំនុំជម្រះជាមិនខាន។ ការបដិសេធរបស់ អ.ជ.ស.ដ មិនព្រមអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ធ្វើឲ្យខូចប្រយោជន៍របស់ ស.ព.អ និងភាគីផ្សេងៗទៀតនៃសំណុំរឿង ០០៤/២ ដោយសារវារំលោភលើសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ក្នុងការទទួលបានភាពត្រឹមត្រូវផ្នែកនីតិវិធី តម្លាភាព សិទ្ធិទទួលបានការស្តាប់សវនាការ និងសច្ចភាពផ្លូវច្បាប់[95]។ កំហុសរបស់ អ.ជ.ស.ដ មានលក្ខណៈមិនសមហេតុផល និងមិនយុត្តិធម៌ទាល់តែសោះ ដែលវាមានតម្លៃស្មើទៅនឹងការរំលោភឆន្ទានុសិទ្ធិ។ បន្ថែមលើនេះ កំហុសអង្គច្បាប់របស់ អ.ជ.ស.ដ ធ្វើឲ្យមោឃៈដល់ការរំលត់កិច្ចដំណើរការនីតិវិធីជាធរមានរបស់ខ្លួន។ ទាំងពីរនេះ ចាំបាច់ធានាឲ្យមានការអន្តរាគមន៍ពី អ.ជ.ត.ក។

## ៣. អ.ជ.ស.ដ មានកំហុសអង្គច្បាប់ និងបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលខ្លួនខកខាន មិនបានអនុវត្តតាមច្បាប់នីតិវិធីត្រឹមត្រូវ និងបានដាក់ចេញដោយចិត្តឯងនូវវិធានការរដ្ឋបាល ដែលមិនតម្រូវពីមុន ដោយបានរារាំងយ៉ាងមានប្រសិទ្ធិភាពមិនឲ្យសំណុំរឿង ០០៤/២ ដំណើរការទៅជំនុំជម្រះបាន

62. អ.ជ.ស.ដ មានកំហុសផ្នែកច្បាប់នៅពេលខ្លួនខកខានមិនបានអនុវត្តតាមការអនុវត្តផ្នែកនីតិវិធីដែលមានស្រាប់ ដែលត្រូវបានទទួលយកសម្រាប់សេចក្តីជូនដំណឹងផ្លូវការនៃសាលដីកាសម្រេច របស់ អ.ប.ជ ក្នុងសំណុំរឿង ០០២ ដោយបានអះអាងផ្ទុយមកវិញថា ខ្លួន “មិនដែលបានទទួលការជូនដំណឹងជាផ្លូវការ” អំពីសំណុំរឿង ០០៤/២ ទេ[96]។ ជាលទ្ធផលនៃការខកខាននេះ អ.ជ.ស.ដ បាន

កថាខណ្ឌ ២ (កត់សម្គាល់ថា អ.ប.ជ បានបញ្ជូនជាផ្លូវការនូវសំណុំរឿងទៅកាន់ ក្រឡាបញ្ជី អ.ជ.ស.ដ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១)។ ដីកាបង្គាប់នេះ បានធ្វើយ៉ាងច្បាស់លាស់ថា ការទទួលយក និង ការបញ្ជូនសំណុំរឿង គឺជាអំពើកម្មដាច់ដោយឡែក - ការទទួលយក *គឺប្រគល់យុត្តាធិការឲ្យទៅ* អ.ជ.ស.ដ ហើយការបញ្ជូន សំណុំរឿង គឺជាផលវិបាកខាងរដ្ឋបាលមួយនៃការទទួលយកនោះ។ *សូមមើលបន្ថែមទៀត* ការពិភាក្សានៅក្នុងកថាខណ្ឌ ៥០-៥៧ *ខាងលើ* ស្តីពី អ.ជ.ស.ដ ត្រូវបានប្តឹងឲ្យទទួលយកសំណុំរឿង០០៤/២ ចាប់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ និងកថាខណ្ឌ ២១, ២៩ ពាក់ព័ន្ធនឹងការអះអាងរបស់ អ.ជ.ស.ដ ថាមានតែ អ.ប.ជ ប៉ុណ្ណោះ ដែលអាចផ្តួចផ្តើមអំពើកម្មបញ្ជូនសំណុំរឿងបាន។

[95] *សូមមើលផងដែរ* ការពិភាក្សាពាក់ព័ន្ធនឹងការរំលោភលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៧១ *ខាងលើ*។

[96] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២។ អ.ជ.ស.ដ មិនធ្លាប់បានពន្យល់ថា ហេតុអ្វីបានជាខ្លួនពិចារណាថា ខ្លួនមិនធ្លាប់បាន ជូនដំណឹងជាផ្លូវការពីសំណុំរឿងនេះ ប៉ុន្តែដោយមិនគិតពីទម្រង់ការណ៍ជាអ្វីនោះទេ ការអះអាងរបស់ អ.ជ.ស.ដ គឺតាមច្បាប់ ខុសស្រឡះ។

ប្រព្រឹត្តកំហុសជាក់ស្តែងមួយក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានដាក់ចេញដោយចិត្តឯងនូវវិធានការរដ្ឋបាលបន្ថែម ដែលមិនត្រូវបានតម្រូវពីមុនមក ដើម្បីឱ្យមានឥទ្ធិពលទៅលើការជូនដំណឹងផ្លូវការនៃសេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២។ កំហុសនេះបានប៉ះពាល់ដល់ ស.ព.អ និងភាគីដទៃទៀតនៃសំណុំរឿង ០០៤/២ ដោយហេតុថា វាបានរាំងខ្ទប់មិនឱ្យសំណុំរឿង ០០៤/២ នេះបន្តទៅជំនុំជម្រះបាន ហេតុដូច្នេះបានរំលោភសិទ្ធិទទួលបាននូវភាពត្រឹមត្រូវផ្នែកនីតិវិធី សច្ចភាពផ្នែកច្បាប់ និងតម្លាភាព និងសិទ្ធិប្តឹងសាទុក្ខ។ កំហុសរបស់ អ.ជ.ស.ដ ធ្វើឱ្យមោឃៈសេចក្តីសម្រេចរបស់ខ្លួន និងបង្កើតបានជាការរំលោភឆន្ទានុសិទ្ធិ។

63. នៅក្នុងសំណុំរឿង ០០២ ការបង្គាប់របស់ អ.ជ.ស.ដ ទៅកាន់ភាគីនានាឱ្យរៀបចំសម្ភារសម្រាប់ការជំនុំជម្រះ ("ដីកាបង្គាប់រៀបចំសវនាការរបស់ អ.ជ.ស.ដ") ដោយបានកត់សម្គាល់ថា អ.ជ.ស.ដ បានទទួលសំណុំរឿងនេះនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១[97] ដែលជាកាលបរិច្ឆេទដែលសាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ត្រូវបានចេញ និងជូនដំណឹង[98]។ សេចក្តីជូនដំណឹងត្រូវបានធ្វើឡើង នៅពេលដែលមន្ត្រីទទួលបន្ទុកសំណុំរឿងបញ្ជូនសារអេឡិកត្រូនិចស្តីពីការជូនដំណឹងផ្លូវការនៃសាលដីកានីមួយៗ ដោយបានចម្លងជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង[99]។ គួរកត់សម្គាល់ថា ចៅក្រម អ.ជ.ស.ដ មិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះទទួលសារអេឡិចត្រូនិករបស់មន្ត្រីទទួលបន្ទុកសំណុំរឿងទេ ប៉ុន្តែ អ.ជ.ស.ដ ចាត់ទុក

---

[97] សំណុំរឿង០០២-ឯកសារ **E9** ដីកាបង្គាប់ឱ្យត្រៀមរៀបចំសវនាការរបស់ អ.ជ.ស.ដ សេចក្តីផ្តើម ត្រង់ KH 00635748។

[98] ដូចដែលបានស្នើសុំនៅកាលបរិច្ឆេទនោះថា សំណុំរឿងនោះត្រូវបានបញ្ជូនតាមផ្លូវច្បាប់ទៅកាន់ អ.ជ.ត.ក គឺថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។ *សូមមើល* សំណុំរឿង០០២-ឯកសារ **E9** ដីកាបង្គាប់ឱ្យត្រៀមរៀបចំសវនាការរបស់ អ.ជ.ស.ដ កថាខណ្ឌ ២។ សំណុំរឿង ០០២-**E313** សាលក្រមសំណុំរឿង ០០១, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ ២៣ ("អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្តឹងឱ្យទទួលយកសំណុំរឿងនេះ បន្ទាប់ពីដំណោះស្រាយគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១")។ សំណុំរឿង ០០២-**E465** សាលក្រមសំណុំរឿង ០០២, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, កថាខណ្ឌ ៣៣។

[99] *សូមមើល* បញ្ជីជូនដំណឹងផ្លូវការរបស់មន្ត្រីកាន់សំណុំរឿង៖ សំណុំរឿង០០២-ឯកសារ **D427/1/26** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ត្រង់ម៉ោង ១:៥៨ រសៀល (*បានភ្ជាប់ជាឧសម្ព័ន្ធ ក១*)។ សំណុំរឿង០០២-ឯកសារ **D427/2/12** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ត្រង់ម៉ោង ២:០០ រសៀល (*បានភ្ជាប់ជាឧសម្ព័ន្ធ ក២*)។ សំណុំរឿង០០២-ឯកសារ **D427/3/12** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ត្រង់ម៉ោង ២:០២ រសៀល (*បានភ្ជាប់ជាឧសម្ព័ន្ធ ក៣*)។ សំណុំរឿង០០២-ឯកសារ **D427/4/14** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ត្រង់ម៉ោង ២:១១ រសៀល (*បានភ្ជាប់ជាឧសម្ព័ន្ធ ក៤*)។

ថា ខ្លួនបានទទួលការជូនដំណឹងជាផ្លូវការអំពីសាលដីកាទាំងនោះ ដោយផ្អែកលើមូលដ្ឋាននៃការទទួលបានរបស់ក្រឡាបញ្ជីនូវការជូនដំណឹងតាមសារអេឡិកត្រូនិចទាំងនោះ។

64. ការអនុវត្តដែលបានធ្វើឡើងដោយ អ.ជ.ស.ង នៅក្នុងដីកាបង្គាប់រៀបចំសវនាការរបស់ អ.ជ.ស.ង នេះ គឺស្របគ្នានឹងមាត្រា ២.១ និង ២.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[100]។ មាត្រា ២.១ ចែងថាការដាក់ឯកសារត្រូវធ្វើផ្ទាល់ទៅកាន់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះ តាមរយៈមន្ត្រីទទួលបន្ទុកសំណុំរឿង។ បទប្បញ្ញត្តិនេះបញ្ជាក់ច្បាស់ថាក្រឡាបញ្ជីគឺជាយន្តការផ្លូវការសម្រាប់ការជូនដំណឹងទៅកាន់ចៅក្រមនៃ អ.ជ.ស.ង។ ស្របគ្នាទៅនឹងតួនាទីនេះ គឺក្រឡាបញ្ជីនៃ អ.ជ.ស.ង ដែលជាអ្នកបញ្ជូនសារអេឡិចត្រូនិកថ្ងៃទី២១ ខែមករា ថ្ងៃទី១០ ខែកុម្ភៈ និងថ្ងៃទី៣ ខែមេសា ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង ដើម្បីបញ្ជូនទស្សនៈរបស់ចៅក្រមទៅកាន់ភាគីនានា[101]។

65. មាត្រា ២.៤ នៃសេចក្តីណែនាំអនុវត្ត នៅពេលអានរួមគ្នាជាមួយនឹងមាត្រា ២.១ ផ្តល់ការណែនាំបន្ថែមអំពីដំណើរការជូនដំណឹងជាផ្លូវការ។ វាចែងថា ឯកសារដែលបានដាក់នៅចំពោះមុខ អ.វ.ត.ក ត្រូវបញ្ជូនទៅកាន់មន្ត្រីទទួលបន្ទុកសំណុំរឿង ដែលត្រូវបញ្ជូនឯកសារនោះភ្លាមទៅកាន់ក្រឡាបញ្ជីដែលពាក់ព័ន្ធ ដូចមានចែងក្នុងវិធានផ្ទៃក្នុង[102]។ និយាយម្យ៉ាងទៀត ឯកសារដែលបានដាក់ដែលបានបញ្ជូនទៅកាន់មន្ត្រីទទួលបន្ទុកសំណុំរឿងនោះ តម្រូវឲ្យជូនដំណឹងភ្លាមៗ (តាមរយៈសារអេឡិចត្រូនិក)ទៅកាន់ក្រឡាបញ្ជី *មិនមែន*ទៅកាន់ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះជាលក្ខណៈបុគ្គលនោះទេ។

66. ជាចុងក្រោយ គុណវុឌ្ឍិភាពនៃវិធាន ៧៧(១៤) អំពីថាតើនរណាខ្លះ ក្រៅពីមនុស្សដែលបានបញ្ជាក់នៅក្នុងវិធាននេះ អាចនឹងត្រូវបានជូនដំណឹងអំពីសាលដីកា (ឬ សេចក្តីពិចារណា) របស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍នោះ មិនគួរត្រូវបានបកស្រាយដើម្បីរារាំងសេចក្តីជូនដំណឹងជាផ្លូវការ ទៅកាន់អ្នកដែលមិនត្រូវបានរៀបរាប់នៅក្នុងវិធាននោះទេ[103]។ ប្រសិនបើ សេចក្តីជូនដំណឹងជាផ្លូវការហួសពីអ្វីដែលបានរៀបរាប់ចំៗពិតជាត្រូវបានហាមឃាត់នោះ អ.ប.ជ នឹងមិនត្រូវបានអនុញ្ញាតឲ្យជូនដំណឹង

---

[100] សេចក្តីណែនាំអនុវត្តឲ្យដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨ បានធ្វើវិសោធនកម្មកាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ (“សេចក្តីណែនាំអនុវត្ត”)។

[101] ដូចដែលបានរៀបរាប់យ៉ាងពិស្តារនៅក្នុងកថាខណ្ឌ ១២, ២១ និង ២៩ *ខាងលើ*។

[102] សេចក្តីណែនាំអនុវត្ត មាត្រា ២.៤។

[103] *ផ្ទុយពី* ឯកសារ **D359/34 & D360/43** អនុស្សរណៈថ្ងៃទី២៩ ខែមករា របស់ប្រធាន អ.ប.ជ ទំព័រទី២។ បន្ថែមពីនេះ ដូចដែលឧទាហរណ៍ក្នុងសំណុំរឿង០០២ បានឆ្លុះបញ្ចាំងដូច្នោះដែរ សេចក្តីជូនដំណឹងតាមផ្លូវការទៅកាន់ក្រឡាបញ្ជី អ.ជ.ស.ង ត្រូវបានពិចារណាថាមានសុពលភាព ទោះជាមានបទប្បញ្ញត្តិនៃវិធាន ៧៧(៤) នៃវិធានផ្ទៃក្នុងក៏ដោយ។

អំពីសាលដីការបស់ខ្លួន ឬសេចក្តីពិចារណារបស់ខ្លួនទៅកាន់សាធារណៈជនទេ ដោយសារតែការណ៍នោះនឹងទៅហួសពី ស.ច.ស សហព្រះរាជអាជ្ញា និង "ភាគីផ្សេងទៀត" ដែលបានបញ្ជាក់ក្នុងវិធានផ្ទៃក្នុង។ ច្បាស់ណាស់ នោះមិនមែនជាករណីនេះទេ ហើយអំណះអំណាងបែបនេះត្រូវតែបរាជ័យ។

67. ស.ព.អ សន្និដ្ឋានថា អ.ជ.ស.ដ មានកំហុសក្នុងរឿងក្តីនេះ ដោយការខកខានមិនបានអនុវត្តនីតិវិធីដែលបានអនុវត្តតាមក្នុងសំណុំរឿង ០០២។ ប្រសិនបើ អ.ជ.ស.ដ បានអនុវត្តច្បាប់ត្រឹមត្រូវនោះ ម៉្លេះខ្លួននឹងបានសន្និដ្ឋានថា អ.ជ.ស.ដ ទទួលបានការជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណារបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២ នៅពេលមន្ត្រីទទួលបន្ទុកសំណុំរឿងបានបញ្ជូនសេចក្តីជូនដំណឹងតាមសារអេឡិចត្រូនិកផ្លូវការនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៤:៥៣ នាទីល្ងាច ដែលបានចម្លងជូនក្រុមមេធាវី អ.ជ.ស.ដ[104]។ សំណួរថាតើមានចៅក្រម អ.ជ.ស.ដ ណាម្នាក់ ឬទាំងអស់ត្រូវបានបញ្ចូលទៅក្នុងបញ្ជីអ្នកទទួលឯកសារផងដែរ ឬយ៉ាងណានោះ គឺមិនទាក់ទងទៅនឹងការកំណត់នេះទេ ហើយការដាក់បញ្ចូលរបស់ក្រុមមេធាវី អ.ជ.ស.ដ ទៅក្នុងសេចក្តីជូនដំណឹង នឹងមិនត្រូវបានចាត់ទុកថា ត្រូវបានហាមឃាត់ដោយវិធាន ៧៧(១៤) ឡើយ។

68. ទោះជាយ៉ាងណា ដោយហេតុថា អ.ជ.ស.ដ ខកខានមិនបានអនុវត្តនីតិវិធីត្រឹមត្រូវ ដើម្បីបង្កើតបានជាសេចក្តីជូនដំណឹងជាផ្លូវការនោះ ខ្លួនបដិសេធមិនទទួលស្គាល់ពីសារសំខាន់នៃសារអេឡិចត្រូនិកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ របស់មន្ត្រីទទួលបន្ទុកសំណុំរឿង ចម្លងជូនក្រុមមេធាវី អ.ជ.ស.ដ ហើយផ្ទុយទៅវិញ បានអះអាងដដែលៗថា ខ្លួនមិនដែលបានទទួលការជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណារបស់ អ.ប.ជ ទេ[105]។ ក្រោយមក អ.ជ.ស.ដ បានប្រើនូវកង្វះការជូនដំណឹងជាផ្លូវការដូចបានចោទប្រកាន់នេះ ជាយុត្តិកម្មមួយផ្នែកសម្រាប់ភាពនៅស្ងៀមរបស់ខ្លួន ក្នុងការសម្រេចលើសារណានៅចំពោះមុខខ្លួន និងបានកំណត់ថាខ្លួនមិនមានយុត្តាធិការ ដែលជាការរាំងខ្ទប់យ៉ាងមានប្រសិទ្ធិភាពមិន

---

[104] *សូមមើល* សេចក្តីជូនដំណឹងតាមសារអេឡិចត្រូនិចពីមន្ត្រីកាន់សំណុំរឿង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ម៉ោង៖ ៤:៥៣ រសៀល (*បានភ្ជាប់ជាឧសម្ព័ន្ធ ខ*)។

[105] ឯកសារ **D359/36.2 & D360/45.2** សារអេឡិចត្រូនិចថ្ងៃទី២១ ខែមករា របស់ក្រុមមេធាវី អ.ជ.ស.ដ ("រហូតមកដល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលសេចក្តីពិចារណា [...] នៅឡើយទេ")។ ឯកសារ **D359/36.8 & D360/45.8** សារអេឡិចត្រូនិចថ្ងៃទី១០ ខែកុម្ភៈ របស់ក្រុមមេធាវី អ.ជ.ស.ដ ("*អង្គជំនុំជម្រះសាលាដំបូង* នៅតែមិនទាន់ទទួលបាន *ការជូនដំណឹងជាផ្លូវការ* អំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ នៅឡើយទេ")។ សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២ ("អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា អង្គជំនុំជម្រះមិនដែលបានទទួលការជូនដំណឹងជាផ្លូវការអំពីសំណុំរឿងនេះទេ")។

ឲ្យរឿងក្តីនេះដំណើរការទៅមុខបាន[106]។ ម្យ៉ាងវិញទៀត អ.ជ.ស.ដ បានប្រដូចទាំងខុសនូវវិធានការរដ្ឋបាលនៃការជូនដំណឹងជាផ្លូវការ ទៅនឹងបុរេលក្ខខណ្ឌផ្នែកយុត្តាធិការ។ ស.ព.អ កត់សម្គាល់ថា សេចក្តីជូនដំណឹងផ្លូវការ គឺជាកិច្ចរដ្ឋបាល *ដែលកើតចេញដោយផ្ទាល់ពី* អ.ជ.ស.ដ ដែលមានយុត្តាធិការ មិនមែនជាកិច្ចដែល*ផ្តល់ឲ្យ* យុត្តាធិការនោះទេ។ ដូច្នេះ វាមិនមែនជាយុត្តិកម្មមានសុពលភាពសម្រាប់រារាំង អ.ជ.ស.ដ មិនឲ្យដំណើរការសំណុំរឿង ០០៤/២ ទៅជំនុំជម្រះនោះទេ[107]។

69. ទោះជាយ៉ាងណា គេច្បាស់ណាស់ថា អ.ជ.ស.ដ បានដាក់ចេញដោយចិត្តឯងនូវវិធានការរដ្ឋបាលបន្ថែម ដើម្បីសម្រេចបាននូវការជូនដំណឹងជាផ្លូវការក្នុងសំណុំរឿង ០០៤/២ ដែលមិនបានតម្រូវក្នុងសំណុំរឿង ០០២។ ទោះជាយ៉ាងណា អ្វីដែល *មិន* ច្បាស់នោះ គឺថាតើ វិធានការរដ្ឋបាលបន្ថែមទាំងនោះគឺមានអ្វីខ្លះពិតប្រាកដ ដោយសារ អ.ជ.ស.ដ មិនដែលបានពន្យល់ពីមូលហេតុដែលថា ខ្លួនមិនបានចាត់ទុកថាខ្លួនបានទទួលការជូនដំណឹងជាផ្លូវការ[108]។ ដូច្នេះ មិនមាននរណាដឹងថាតើ អ.ជ.ស.ដ បានដាក់លក្ខខណ្ឌលើសេចក្តីជូនដំណឹងស្តីពីការអនុម័តិរបស់ អ.ប.ជ ដោយសំឡេងគាំទ្រលើសលុបក្នុងសេចក្តីណែនាំណា តាមប្រភេទណាមួយ ទៅកាន់ អ.ជ.ស.ដ ឬ ទៅកាន់ផ្នែកគ្រប់គ្រងតុលាការនោះទេ ឬថាតើខ្លួនបានរកឃើញថា សេចក្តីជូនដំណឹងមិនមានលក្ខណៈគ្រប់គ្រាន់ ព្រោះថា ចៅក្រមទាំងអស់នៃ អ.ជ.ស.ដ មិនទទួលបានការជូនដំណឹងជាលក្ខណៈបុគ្គលអំពីសេចក្តីពិចារណារបស់

---

[106] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២៖ "អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញផងដែរថា ឯកសារ សម្ភារៈភាគច្រើននៃសំណុំរឿងនេះគឺមានភាពជាសម្ងាត់ និងយល់ឃើញថា ចំណុចនេះគឺជាបញ្ហាសារធាតុដែលអង្គជំនុំជម្រះសាលាដំបូងពុំមានសិទ្ធិចូលទៅពិនិត្យមើលឯកសារ សម្ភារៈ ទាំងនោះបានឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងក៏មិនអាចមានសិទ្ធិចូលមើលសំណុំរឿងនោះដែរ *លើកលែងតែមានការជូនដំណឹងដោយត្រឹមត្រូវ* ហើយសំណុំរឿងនេះត្រូវបានបញ្ជូនមកឲ្យខ្លួន" (សង្កត់ន័យបន្ថែម)។ ការបញ្ចប់ដ៏មានប្រសិទ្ធិភាពនៃសំណុំរឿងនេះ ត្រូវបានរៀបរាប់ពិស្តារយ៉ាងពេញលេញ នៅក្នុងកថាខណ្ឌ ៤១-៤៥ *ខាងលើ* និងកថាខណ្ឌ ៧១-៧៦ *ខាងក្រោម*។

[107] ដូចដែលបានពិភាក្សានៅក្នុងកថាខណ្ឌ ៥០-៥៧ *ខាងលើ* យុត្តាធិការត្រូវបានប្រគល់បន្តឲ្យទៅ អ.ប.ជ ចាប់តាំងពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ នៅពេលដែល អ.ប.ជ ខកខានមិនសម្រេចបាននូវមតិភាគច្រើនដាច់ខាត ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយ អ.ប.ជ ត្រូវបានប្តឹងឲ្យទទួលយកសំណុំរឿង០០៤/២ អនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង។

[108] *សូមមើល* សំណើសុំឲ្យបញ្ជាក់ឡើងវិញរបស់ ស.ព.អ ជូនទៅ អ.ជ.ស.ដ កថាខណ្ឌ ២១-២៤។ *បានភ្ជាប់ជាឧសម្ព័ន្ធ V1 (ជាភាសាអង់គ្លេស) និង V2 (ជាភាសាខ្មែរ)* ។

អ.ប.ជ តាមរយៈមន្ត្រីទទួលបន្ទុកសំណុំរឿង[109]។ លក្ខខណ្ឌតម្រូវទាំងពីរនេះ រំលោភលើនីតិវិធីដែលមានស្រាប់ និងដែលត្រូវបានទទួលយកពីមុនមក[110]។

70. កំហុសរបស់ អ.ជ.ស.ដ ធ្វើឱ្យគ្មានសុពលភាពដល់ការរលត់ជាធរមាននៃរឿងក្តីនេះ និងបានធ្វើឱ្យខូចដល់ប្រយោជន៍របស់ ស.ព.អ និងភាគីផ្សេងៗទៀតនៃសំណុំរឿង ០០៤/២ តាមរយៈការរំលោភលើសិទ្ធិរបស់ពួកគេក្នុងការទទួលបានភាពត្រឹមត្រូវផ្នែកនីតិវិធី សច្ចភាពផ្លូវច្បាប់ និងតម្លាភាព[111]។ ប្រសិនបើ អ.ជ.ស.ដ បានអនុវត្តច្បាប់ត្រឹមត្រូវ និង/ឬ បានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនបានសមស្រប នោះ សំណុំរឿង ០០៤/២ នេះម្ល៉េះបានដំណើរការទៅជំនុំជម្រះជាមិនខាន។ កំហុសរបស់ អ.ជ.ស.ដ គឺមិនសមហេតុផល និងអយុត្តិធម៌យ៉ាងច្បាស់ក្រឡែត ហើយអន្តរាគមន៍របស់ អ.ជ.ត.ក គឺជាដំណោះស្រាយតែមួយគត់ ដែល ស.ព.អ មាន ដើម្បីដោះស្រាយលទ្ធផលបែបនេះ។

## ៤. អ.ជ.ស.ដ មានកំហុសអង្គច្បាប់ នៅពេលខ្លួនរំលត់សំណុំរឿង ០០៤/២ ជាធរមាន ផ្អែកលើ ទឡ្ហីករណ៍ដែលមិនអាចអនុញ្ញាតបាន

71. នៅក្នុងសេចក្តីថ្លែងការថ្ងៃទី៣ ខែមេសា ចៅក្រមជាតិទាំងបីរូបនៃ អ.ជ.ស.ដ បានបង្ហាញទស្សនៈរបស់ខ្លួនយ៉ាងច្បាស់ថា "នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង ០០៤/២ ពាក់ព័ន្ធ អោ អាន នៅ

[109] វាគឺជាការយល់ឃើញរបស់ ស.ព.អ ដែលថា ចៅក្រមជាតិរបស់ អ.ជ.ស.ដ មិនត្រូវបានជូនដំណឹងពីសេចក្តីពិចារណារបស់ អ.ប.ជ ពីព្រោះនៅពេលដែលសេចក្តីពិចារណាទាំងនោះត្រូវបានចេញ ចៅក្រមជាតិរបស់ អ.ជ.ស.ដ មិនបានទាក់ទងជាមួយនឹង អ.វ.ត.ក ទេ។

[110] ការពិចារណារបស់ អ.ប.ជ ជាញឹកញាប់ពុំមានសេចក្តីណែនាំទៅកាន់ អ.ជ.ស.ដ ឬមួយក៏ទៅកាន់ CMS ពាក់ព័ន្ធទៅនឹងថាតើនរណាត្រូវទទួលនូវការជូនដំណឹងតាមផ្លូវការនោះទេ ក៏នៅឡើយដែរថា រឿងនោះមិនរាប់បញ្ចូលនូវពួកទាំងនោះមិនឱ្យបានទទួលស្គាល់ថាបានជូនដំណឹងជាផ្លូវការ នៅពេលដែលមន្ត្រីកាន់សំណុំរឿងធ្វើការជូនដំណឹងជាផ្លូវការតាមសារអេឡិចត្រូនិច។ *សូមមើល ឧទា.* ឯកសារ **D257/1/8** សេចក្តីពិចារណាលើសំណើរបស់ តា អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ, ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ផ្នែកសេចក្តី សម្រេច (ជាឯកច្ឆ័ន្ទ) ត្រង់ KH 01241279។ ឯកសារ **D239/1/8** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ,* ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ផ្នែកសេចក្តីសម្រេច ត្រង់ KH 01210681។ សំណុំរឿង០០៣-ឯកសារ **D174/1/4** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ [កោស លុប] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ [កោស លុប] ពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់ នៃការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦ ផ្នែកសេចក្តីសម្រេច ត្រង់ KH 01235590។ អង្គហេតុថា រាល់ចៅក្រម អ.ជ.ស.ដ ទាំងអស់ ជាបុគ្គលមិនចាំបាច់ត្រូវបានជូនដំណឹងជាផ្លូវការ ត្រូវបាន ពិភាក្សារួចហើយនៅត្រង់កថាខណ្ឌ ៦៣-៦៧ *ខាងលើ*។

[111] សិទ្ធិជាមូលដ្ឋានទាំងនេះ ត្រូវបានធានាដោយវិធាន២១(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ការពិភាក្សាអំពីការរំលោភលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាននៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៧១ *ខាងលើ* ។

ពេលនេះ ឬនៅពេលអនាគតឡើយ” ហើយចៅក្រម *ទាំងអស់* បានលើកឡើងថា ការចេញសេចក្តីសម្រេចជាផ្លូវការមួយ“មិនអាចធ្វើបានទេ”[112]។ ភាពនៅស្ងៀមរបស់ អ.ជ.ស.ជ គឺផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

> អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា អង្គជំនុំជម្រះមិនដែលបានទទួលការជូនដំណឹងជាផ្លូវការអំពីសំណុំរឿងនេះទេ ហើយអង្គជំនុំជម្រះមិនបានទទួលសំណុំរឿងនេះឡើយ។ [...] អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញផងដែរថា ភាគច្រើននៃសំណុំរឿងនេះគឺមានភាពសម្ងាត់ និងយល់ឃើញថា ចំណុចនេះគឺជាបញ្ហាសារធាតុដែលអង្គជំនុំជម្រះសាលាដំបូង ពុំមានសិទ្ធិចូលពិនិត្យមើលឯកសារ សម្ភារៈ ទាំងនោះបាន ហើយអង្គជំនុំជម្រះសាលាដំបូង ក៏មិនអាចមានសិទ្ធិចូលមើលសំណុំរឿងនោះដែរ *លើកលែងតែ និងទាល់តែមានការជូនដំណឹង និងការបញ្ជូនសំណុំរឿងនេះដោយត្រឹមត្រូវ*[113]។

72. យើងត្រូវតែកត់សម្គាល់ថា សេចក្តីថ្លែងការណ៍នេះ ត្រូវបានធ្វើឡើង<u>ក្រោយពេលដែល</u> អ.ជ.ស.ជ បានលើកយោងអនុស្សរណៈថ្ងៃទី១៦ ខែមីនា ដែលនៅក្នុងនោះប្រធាន អ.ប.ជ បានថ្លែងថា អ.ប.ជ នឹងមិនចាត់វិធានការរដ្ឋបាលណាមួយបន្ថែមទៀត ដើម្បីជូនដំណឹងទៅ អ.ជ.ស.ជ ឬ បញ្ជូនសំណុំរឿងនេះឡើយ[114]។ និយាយម្យ៉ាងវិញទៀត អ.ជ.ស.ជ បាននិយាយថា ខ្លួននឹងមិនបំពេញកិច្ចដោយមិនមានវិធានការរដ្ឋបាល ដែលខ្លួនបានដឹងយ៉ាងច្បាស់ថានឹងមិនអាចកើតមាននោះ។ ការណ៍នេះបានរំលត់កិច្ចដំណើរការនីតិវិធីជាធរមាន ផ្អែកលើមូលដ្ឋានដែលមិនត្រូវបានអនុញ្ញាតដោយច្បាប់។ ដូច្នេះ អ.ជ.ស.ជ បានប្រព្រឹត្តកំហុសអង្គច្បាប់ និងបានបំពេញកិច្ចក្រៅសិទ្ធិអំណាចផ្លូវច្បាប់របស់ខ្លួន ដែលធ្វើឱ្យសេចក្តីសម្រេចរបស់ខ្លួនទៅជាមោឃៈ។

73. ទទ្បីករណ៍ច្បាប់សម្រាប់ការរំលត់បណ្តឹងអាជ្ញានៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ មិនត្រូវបានដោះស្រាយដោយវិធានផ្ទៃក្នុងឡើយ។ ក្នុងស្ថានភាពបែបនេះ វិធាន ២ នៃវិធានផ្ទៃក្នុង បានតម្រូវឱ្យអង្គជំនុំជម្រះសម្រេចលើបញ្ហានានា ស្របតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ៣៣ថ្មី និង ៣៧ថ្មី នៃច្បាប់ អ.វ.ត.ក[115]។ ក្នុងបទប្បញ្ញត្តិទាំងអស់នេះ “នីតិវិធីត្រូវស្រប

---

[112] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២។

[113] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២ (សង្កត់ន័យបន្ថែម)។

[114] សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣ ខែមេសា ទំព័រទី២។

[115] *សូមមើល* វិធាន២ នៃវិធានផ្ទៃក្នុង។

ជាមួយច្បាប់កម្ពុជា” និងនៅពេលដែលច្បាប់កម្ពុជាមិនដោះស្រាយបញ្ហានេះ គេអាចស្វែងរកការណែនាំក្នុងវិធាននីតិវិធី ដែលបានបង្កើតនៅក្នុងកម្រិតអន្តរជាតិ។

74. ច្បាប់នីតិវិធីកម្ពុជាចែងថា បណ្តឹងអាជ្ញាអាចរលត់ដោយសារមរណភាពរបស់ជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ ឬ *អាជ្ញាអស់ជំនុំ*[116]។ អ.ជ.ត.ក និង អ.ជ.ស.ដ ទាំងពីរ បានសម្រេចថា អ.វ.ត.ក មិនមានសិទ្ធិអំណាចបង្គាប់ឲ្យរំលត់បណ្តឹងអាជ្ញាដោយមូលហេតុណាផ្សេងពីនេះឡើយ[117]។ ចំពោះវិធានដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ការរំលត់បណ្តឹងអាជ្ញា ឬការផ្អាកកិច្ចដំណើរការនីតិវិធី ជួនកាលត្រូវបានអនុញ្ញាតដោយតុលាការផ្សេងទៀត ប៉ុន្តែឧទាហរណ៍ទាំងនេះមានតិចតួច និងឆ្លុះបញ្ចាំងពីស្ថានភាពដែលថា ការបញ្ឈប់ត្រូវបានចាត់ទុកថា ជាឧបាស្រ័យ *តែមួយគត់* ដែលមានសមត្ថភាពក្នុងការធានានូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ឬបើមិនដូច្នោះទេ ជាផលប្រយោជន៍នៃយុត្តិធម៌[118]។ គ្មានចំណុចណាក្នុងចំណោមចំណុចទាំងនេះអនុវត្តបានចំពោះសំណុំរឿង ០០៤/២ ឡើយ។

---

[116] CCCP មាត្រា៧។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ មាត្រា៦ (*“L’action publique pour l’application de la peine s’éteint par la mort du prévenu, la prescription, l’amnistie, l’abrogation de la loi pénale et la chose jugée.”*)។ បកប្រែក្រៅផ្លូវការ៖ “កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវបានរំលត់ដោយ មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និង *អាជ្ញាអស់ជំនុំ*”)។

[117] សំណុំរឿង០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨។ សំណុំរឿង០០២-ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-១៧ (ដោយរកឃើញថា កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក អាចត្រូវបានបញ្ចប់នៅក្រោមវិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុង នៅលើទឡ្ហីករណ៍មួយក្នុងចំណោមទឡ្ហីករណ៍ដែលមានកម្រិត ដែលមានចែងនៅក្នុងមាត្រា៧ នៃ CCCP)។

[118] *សូមមើល ឧទា. រដ្ឋអាជ្ញា ទល់នឹង* *Karadžić* សំណុំរឿង IT-95-5/18-T សេចក្តីសម្រេចលើញត្តិស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ ៤ (ដោយទទួលស្គាល់ថា ដំណោះស្រាយជាទីបំផុតនៃការផ្អាកកិច្ចដំណើរការនីតិវិធី អាចនឹងត្រូវបានអនុញ្ញាតឲ្យ កាលណាមានការបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សរបស់ជនជាប់ចោទ ដែលធ្វើឲ្យការកាត់ក្តីដ៏ត្រឹមត្រូវមួយ មិនអាចប្រព្រឹត្តទៅបាន)។ *រដ្ឋអាជ្ញា ទល់នឹង* *Lubanga Dyilo* សំណុំរឿង ICC-01/04-01/06-772 សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការ អនុលោមតាម មាត្រា១៩(២)(ក) នៃច្បាប់លក្ខន្តិកៈចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០។

75. វិធាន២ នៃវិធានផ្ទៃក្នុង ក៏តម្រូវឱ្យ អ.ជ.ស.ដ "ផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង" ដែលរួមទាំងកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ និងចំពោះមុខ ដែលរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគី និងការធានាថា ជនរងគ្រោះត្រូវបានជូនដំណឹងនិងថាសិទ្ធិរបស់ពួកគេត្រូវបានគោរពនៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងមូល[119]។ ការរំលត់ជាធរមានរបស់ អ.ជ.ស.ដ នៃកិច្ចដំណើរការនីតិវិធីនេះ បានរំលោភលើគោលការណ៍ទាំងអស់នេះ[120]។

76. កំហុសអង្គច្បាប់របស់ អ.ជ.ស.ដ ធ្វើឱ្យមោឃៈដល់សេចក្ដីសម្រេចរបស់ខ្លួន ដើម្បីរំលត់កិច្ចដំណើរការនីតិវិធី និងចាំបាច់ត្រូវមានអន្តរាគមន៍ពី អ.ជ.ត.ក។ ស.ព.អ ស្នើសុំដោយគោរពឱ្យ អ.ជ.ត.ក ផ្លាស់ប្ដូរ និងកែតម្រូវសេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្របតាមច្បាប់ត្រឹមត្រូវ ដូចបានពិភាក្សាយ៉ាងពេញលេញក្នុងផ្នែកខាងដើម។

## IV. ឧបាស្រ័យដែលស្នើសុំ

77. សម្រាប់មូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឱ្យ អង្គជំនុំជម្រះតុលាការកំពូល៖

ក. ទទួលយកបណ្ដឹងសាទុក្ខបន្ទាន់នេះថា អាចទទួលយកបាន។

ខ. បង្គាប់ឱ្យបញ្ជូនសំណុំរឿង ០០៤/២ នេះ ទៅ អ.ជ.ត.ក សម្រាប់គោលបំណងបណ្ដឹងសាទុក្ខនេះ។

គ. សម្រេចថា អ.ជ.ស.ដ ត្រូវបានប្ដឹងឱ្យទទួលយកសំណុំរឿង ០០៤/២ នេះ និងបង្គាប់ឱ្យ អ.ជ.ស.ដ បើកសវនាការលើសំណុំរឿងនេះយ៉ាងឆាប់បំផុត ដោយបង្គាប់ឱ្យមានវិធានការរដ្ឋបាលណាមួយដែលពាក់ព័ន្ធទៅនឹងចំណាក់ការនេះ រួមទាំងការបញ្ជូនសំណុំរឿងនេះ (និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ពី អ.ជ.ត.ក ទៅ អ.ជ.ស.ដ។

---

119 វិធាន ២, ២១(១)(ក-គ) នៃវិធានផ្ទៃក្នុង។

120 *សូមមើល ខទ.* កថាខណ្ឌ ២៩-៣០, ៤៣-៤៤, *ខាងលើ*, ពិភាក្សាពីការមិនមានតម្លាភាពរបស់ អ.ជ.ស.ដ និងការខកខានមិនបានពិចារណាលើសារណារបស់របស់ភាគីនានាតាមផ្លូវណាមួយ ហើយនិង កំណត់សម្គាល់ជើងទំព័រលេខ ៧១ *ខាងលើ* ពិភាក្សាអំពីការរំលោភយ៉ាងធ្ងន់ធ្ងរ និងច្រំដែលៗ ទៅលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ នៅក្នុងសំណុំរឿង ០០៤/២។

ឃ. ទទួលស្គាល់ការរំលោភយ៉ាងធ្ងន់ធ្ងរ និងជាច្រើនដង លើសិទ្ធិរបស់ ស.ព.អ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ និងដោះស្រាយជូនពួកគេឲ្យបានសមស្រប។

ង. បង្គាប់ថា សារណារបស់ភាគីទាំងអស់ ដែលត្រូវបានបញ្ជូនត្រឡប់មកវិញដោយ អ.ជ.ស.ជ ត្រូវតែសម្រេចតាមផ្លូវតុលាការឲ្យបានត្រឹមត្រូវ មិនលម្អៀង និងឯករាជ្យដោយ អ.ជ.ស.ជ ស្របតាមច្បាប់ និងអង្គហេតុនៃរឿងក្តីនេះ។

ច. បង្គាប់ថា សារណារបស់ភាគីទាំងអស់ ត្រូវបានចុះលេខឯកសារ និងជូនដំណឹងជាសាធារណៈ ដើម្បីស្តារឡើងវិញនូវតម្លាភាព និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។

ឆ. ចេញសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញជាសាធារណៈ ដែលនឹងផ្តល់នូវសច្ចភាពផ្លូវច្បាប់ និងស្តារឡើងវិញនូវមុខងាររបស់តុលាការនេះឲ្យទៅជាតុលាការមួយ ដែលធ្វើសេចក្តីសម្រេចប្រកបដោយតម្លាភាព ផ្អែកតាមច្បាប់ និងអង្គហេតុនៅចំពោះមុខខ្លួន៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ | **លោកស្រី** **Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |